# ផែនការសកម្មភាព ២០០៧-២០១០

# ព្រៃឈើ និង បរិស្ថាន

## ផែនការ និង គំរោងថវិកា ឆ្នាំ ២០០៧

(ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០០៦-២០១០)



ក្រុមការងារបច្ចេកទេសព្រៃឈើ និង បរិស្ថាន

ខែ ធ្នូ ឆ្នាំ ២០០៦

# បុព្វកថា

រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវអាទិភាពសំរាប់ការអភិវឌ្ឍន៍ នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(NSDP) សំរាប់ឆ្នាំ២០០៦-២០១០។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិត្រូវបានដកស្រង់ចេញពីយុទ្ធសាស្ត្រផ្សេងៗ រួមមាន: យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ និងយុទ្ធសាស្ត្រចតុកោណ។ ការកាត់បន្ថយភាពក្រីក្រ និងការបង្កើនសេដ្ឋកិច្ចជាតិ គឺជាគោលដៅចំបងនៃការអភិវឌ្ឍន៍ប្រទេសកម្ពុជា ។

ប្រទេសកម្ពុជាមានប្រជាជនប្រហែលជា ៩០%រស់នៅតាមតំបន់ជនបទ ដែលព្រៃឈើគ្របដណ្តប់ ៦០%នៃផ្ទៃដីប្រទេស ទើបកត្តាជោគជ័យនៃគោលដៅចំបងៗថ្នាក់ជាតិ គឺមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងការអភិវឌ្ឍន៍ជីវភាពរបស់ប្រជាជននៅជនបទដែលពឹងផ្អែកលើធនធានព្រៃឈើ។ ផ្អែកលើកត្តាទាំងនេះ រាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញាចិត្តធ្វើការអភិរក្ស និងគ្រប់គ្រងធនធានព្រៃឈើកម្ពុជាប្រកបដោយចីរភាព ។

កាប្រើប្រាស់វិធីសាស្ត្រសំរបសំរួល គឺជាដំណោះស្រាយរួមមួយដើម្បីសំរេចនូវគោលដៅខាងលើ ក្នុងនោះក៏តំរូវឱ្យជំរុញការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព ដើម្បីជាប្រយោជន៍ដល់ជីវភាពប្រជាជនតាមជនបទ។ ទន្ទឹមនេះ ក៏បានថែរក្សាធនធានឱ្យស្ថិតនៅដំណាក់កាលផលិតកម្មដំបូង។ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតក្រុមការងារបច្ចេកទេសព្រៃឈើនិងបរិស្ថានដើម្បីធានានូវការសំរបសំរួលនិងអភិវឌ្ឍន៍វិស័យព្រៃឈើ។ ក្រុមការងារបច្ចេកទេសព្រៃឈើ និងបរិស្ថាន ទទួលភារកិច្ចរៀបចំផែនការសកម្មភាពរួមរយៈពេល៤ឆ្នាំមួយ សំរាប់ធ្វើជាគោលក្នុងការសំរួលដល់ការរៀបចំផែនការរយៈពេលមធ្យម។ ផែនការនេះក៏ឆ្លុះបញ្ចាំងនូវសកម្មភាពអាទិភាពនៅក្នុងវិស័យព្រៃឈើនេះផងដែរ។

ដីព្រៃកំពុងតែប្រឈមមុខនឹងស្ថានភាពមិនធម្មតា។ ម្យ៉ាងយើងបានទទួលស្គាល់ជាទូទៅថា លក្ខខ័ណ្ឌជីវភាពនៅជនបទ សិទ្ធប្រើប្រាស់ផល និងទទួលសេវាកម្មព្រៃឈើនានា គឺត្រូវតែអភិវឌ្ឍន៍ក្នុងពេលជាមួយគ្នា ពោលគឺ ដើម្បីធ្វើឱ្យជីវភាពនៅជនបទមានចិរភាព។ ការស្រាវជ្រាវមួយបានបង្ហាញឱ្យឃើញថា ប្រសិនបើសហគមន៍ជនបទនានាមានជំរើស នោះលទ្ធភាពទទួលបានផលព្រៃឈើ និងសេវាកម្មនានា គឺពិតជាកើនឡើងជាមិនខាន។ ម្យ៉ាងវិញទៀតព្រៃឈើកំពុងតែស្ថិតក្រោមសម្ពាធនានាជាច្រើន ហើយដែលតម្រូវអោយមានវិធានការទប់ស្កាត់។

យើងសង្ឃឹមថា នឹងទទួលបានបទពិសោធន៍ក្នុងការជំរុញការអភិវឌ្ឍន៍ជាតិតាមរយៈការអនុវត្តន៍ផែនការ ៤ឆ្នាំរបស់ក្រុមការងារបច្ចេកទេសព្រៃឈើនិងបរិស្ថាន ហើយក៏ចង់ឃើញថាតើ ផែនការនេះ នឹងបង្កើតគំរូសំរាប់ការរៀបចំផែនការគ្រប់គ្រងធនធានដែលនឹងត្រូវធ្វើឡើង ដោយស្ថាប័នពាក់ព័ន្ធនានាយ៉ាងដូចម្តេច។

យើងខ្ញុំសូមអំពាវនាវចំពោះដៃគូអភិវឌ្ឍន៍នានា មេត្តាផ្តល់នូវការគាំទ្រយ៉ាងពេញទំហឹងដល់ផែនការសកម្មភាព ៤ ឆ្នាំរបស់ក្រុមការងារបច្ចេកទេសព្រៃឈើនិងបរិស្ថាននេះ។ បើសិនមានការគាំទ្រខាងហិរញ្ញវត្ថុ និងបច្ចេកទេសគ្រប់គ្រាន់ និងទាន់ពេលវេលាពីរាជរដ្ឋាភិបាលកម្ពុជា និងសហគមន៍អន្តរជាតិនោះ យើងពិតជាអាចបង្កើនប្រសិទ្ធភាពក្នុងការអនុវត្តន៍ផែនការនេះជាមិនខាន។

ដូចនេះ ខ្ញុំសូមសម្តែងនូវសេចក្តីគោរព និង សំណូមពរដល់សមាជិកក្រុមការងារបច្ចេកទេសព្រៃឈើនិងបរិស្ថានទាំងអស់ និង បណ្តាអ្នកពាក់ព័ន្ធទាំងឡាយ សូមជួយគាំទ្រផែនការនេះ ព្រោះថា នេះជាច្រកផ្លូវមួយដ៏សំខាន់ ដែលនាំទៅរកការអភិវឌ្ឍន៍វិស័យព្រៃឈើកម្ពុជា។

**ឯកឧត្តម ឌី សុគន្ធ**

**ប្រធានក្រុមការងារបច្ចេកទេសព្រៃឈើនិងបរិស្ថាន**

# សេចក្តីថ្លែងអំណរគុណ

ផែនការសកម្មភាព ៤ឆ្នាំ ២០០៧-២០១០ របស់ក្រុមការងារ TWG-F&E ត្រូវបានរៀបចំឡើងដើម្បីសំរួលក្នុងការធ្វើផែនការផ្សេងៗទៀតក្នុងការអភិវឌ្ឍន៏វិស័យព្រៃឈើ ។ ផែនការនេះត្រូវបានបង្កើតឡើង ដោយបានសិក្សាអំពីតំរូវការនានា ក្នុងពេលបច្ចុប្បន្ន និងបានពិនិត្យឡើងវិញនូវទំនាក់ទំនងនានាជាមួយនឹងគោលនយោបាយជាតិពាក់ព័ន្ធ ហើយជាចុងក្រោយគួបផ្សំជាមួយអាទិភាព និងទស្សនៈរបស់សមាជិក និងដៃគូអភិវឌ្ឍន៍នានារបស់ក្រុមការងារ TWG-F&E ។

យើងខ្ញុំសូមថ្លែងអំណរគុណជាពិសេសចំពោះ ឯកឧត្តម លោក លោកស្រី ដែលបានចំណាយពេលវេលាដ៏មានតំលៃក្នុងការជួយពិនិត្យ និងពិចារណា ហើយចង្អុលបង្ហាញនូវគោលការណ៍ល្អៗមួយចំនួន ក្នុងការរៀបចំផែនការនេះ។ ក្នុងនោះរួមមាន **ឯកឧត្តម ទី សុគន្ធ** ប្រធានរដ្ឋបាលព្រៃឈើ និង **លោក ចាយ សាមិត្ត** ប្រធាននាយកដ្ឋានការពារនិងអភិរក្សធម្មជាតិ (DNCP) នៃក្រសួងបរិស្ថាន, លោក Mogens Laumand Christensen, តំណាងអង្គការ DANIDA ប្រចាំនៅកម្ពុជា, លោក បណ្ឌិត Andrew Wardell, DANIDA, លោកស្រី TANAKA Tomoko តំណាងអង្គការ JICA, លោក Hori Masahiko អង្គការ JICA, លោក Yuzuru Kimur អង្គការ JICA, លោក **ឡាយ ឃីម** អង្គការ UNDP, លោក Daniel Costa Llobet គណៈកម្មការសហគមន៍ អឺរ៉ុប (EU), អ្នកស្រី Anna Beloff អង្គការ FAO, លោក បណ្ឌិត Peter Jipp ធនាគារពិភពលោក (World Bank), លោក **សេង ទៀក** អង្គការ WWF, លោក **ឈិត សំអាត** នាយកប្រតិបត្តិនៃអង្គការ NGO Forum, លោក Rusell Piterson ទីប្រឹក្សាអង្គការ NGO Forum, លោក **ហែម វណ្ណាយុទ្ធ** ក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា, លោក **នេត មុន្នី** ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, លោក Joe Walson អង្គការ WCS, លោក **សេង ប៊ុនរ៉ា** អង្គការអភិរក្សអន្តរជាតិ (CI), លោក **អ៊ុក គីមសាន** អង្គការអភិរក្សអន្តរជាតិ (CI), លោក **កៅ ដាណា** អង្គការអភិរក្សអន្តរជាតិ (CI), លោក **សួន សុវណ្ណ** រដ្ឋបាលព្រៃឈើ, លោក **ឃន សាវ៉េត** រដ្ឋបាលព្រៃឈើ, លោក **ស៊ី រ៉ាមុន្នី** នាយកដ្ឋានការពារ និងអភិរក្សធម្មជាតិ, លោក **វណ្ណ សំណាង** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, លោកស្រី **សួន ពិនកណ្ណិកា** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, លោក **សុខ ស៊្រុន** លេខាក្រុមការងារបច្ចេកទេសព្រៃឈើ និងបរិស្ថាន និង អ្នកពាក់ព័ន្ធដទៃទៀត។

Arvid Sloth & **អៀង សាវ៉េត**

ថ្ងៃទី 07 ខែធ្នូ ឆ្នាំ 2006

# ទិដ្ឋភាពទូទៅអំពីធនធានធម្មជាតិ

## សក្តានុពលភាព

ព្រៃឈើគឺជាធនធានធម្មជាតិដ៏សំខាន់បំផុតរបស់កម្ពុជាសំរាប់អភិវឌ្ឍន៍ប្រទេស (ផែនការអភិបាលកិច្ច)។ ធនធានមច្ឆាជាតិនិងធនធានព្រៃឈើ បូកបញ្ចូលគ្នា គឺមានចំនួន ២៩% នៃប្រភពប្រាក់ចំណូលសំរាប់គ្រួសារក្រីក្របំផុត (ចំពោះផលិតផលព្រៃឈើ គឺមាន១៨%)ដែលជាវិភាគទានសំខាន់ទីពីរ បន្ទាប់ពីការបង្កបង្កើនផលកសិកម្ម ក្នុងការទ្រទ្រង់ជីវភាពរបស់ប្រជាជនយើង (ធនាគារពិភពលោក ២០០៦)។

## ឧបសគ្គចំពោះមុខ

ការគ្រប់គ្រងធនធានធម្មជាតិនិងអភិបាលកិច្ច គឺស្ថិតនៅក្នុងដំណាក់កាលមួយដ៏សំខាន់។ អវត្តមាននៃការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងការអនុវត្តច្បាប់ បណ្តាលឱ្យមានការធ្វើអាជីវកម្មដោយអនាធិបតេយ្យ ហើយធ្វើឱ្យប្រជាជនក្រីក្រមួយចំនួនទទួលបានផលបន្តិចបន្តួច និងជម្លោះកាន់កាប់ដីព្រៃ ដែលបង្កជាឧបសគ្គទៅដល់តួនាទីសក្តានុពលរបស់ធនធានធម្មជាតិ ក្នុងការធ្វើអោយជីវភាពប្រជាជននៅតាមជនបទកាន់តែប្រសើរឡើងនោះ។ លើសពីនេះទៅទៀត ការស្វែងរកការជួលក្រៅផ្លូវការ គួបផ្សំនិងការអនុវត្តការចំណាយក្រៅផ្លូវការផ្សេងៗ កំពុងតែបំផ្លាញគុណនេយ្យភាពក្នុងសង្គម។ ការរានយកដីព្រៃពីសំណាក់អ្នកមានអំណាច និងពួកក្រុមអ្នករុករានដី គឺជាសកម្មភាពបំផ្លិចបំផ្លាញមួយថ្មីទៀត។ ភាពទន់ខ្សោយនៃខ្សែបណ្តាញអង្គភាពបច្ចេកទេស និងអាជ្ញាធរដែនដី គួបផ្សំនិងសម្លេងទាមទារនិងឥទ្ធិពលមិនគ្រប់គ្រាន់របស់ប្រជាជនដែលមានជីវភាពពឹងអាស្រ័យលើធនធានធម្មជាតិនោះ បណ្តាលឱ្យគេមិនអាចបញ្ឈប់សកម្មភាពបទល្មើសទាំងនោះបានឡើយ។ ហេតុដូច្នេះ ថ្មីៗកន្លងទៅនេះ ចំណូលដែលទទួលបានពីព្រៃឈើមានការធ្លាក់ចុះ (Danida/ Dfid, 2006, WB. 2006)

## ឱកាស

មានឱកាសច្រើនដើម្បីធ្វើអោយប្រសើរឡើងនូវលក្ខខណ្ឌសេដ្ឋកិច្ចសង្គមរបស់ប្រជាពលរដ្ឋដែលរស់នៅជនបទ តាមរយៈការបង្កើនការយកចិត្តទុកដាក់ និងភាពជាដៃគូ ក្នុងការគ្រប់គ្រងធនធានធម្មជាតិ។ តាមរយៈការជួយជ្រោមជ្រែងពីក្រុមការងារបច្ចេកទេស ការបង្កើតភាពជាដៃគូ និងការបញ្ចូលគ្នានូវអាទិភាពក្នុងចំណោមស្ថាប័នជាតិសំខាន់ៗ រួមជាមួយនិងបណ្តាអ្នកពាក់ព័ន្ធពីខាងក្រៅ ព្រមទាំងកិច្ចសហការពីរាជរដ្ឋាភិបាលដែលជាយន្តការដ៏សំខាន់ក្នុងការសំរបសំរួល និងដោះស្រាយបញ្ហាប្រឈមមុខនានាក្នុងពេលអនាគត។ (RGC 2006a ; RGC 2006b)

# មាតិការ


| | | ទំព័រ |
|---|---|---|
| | **បុព្វកថា** | ២ |
| ១. | **សេចក្តីសង្ខេបនៃក្របខ័ណ្ឌជាយុទ្ធសាស្ត្រសំរាប់ការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និង តួនាទីនៃផែនការសកម្មភាព រយៈពេលវែង របស់ក្រុមការងារបច្ចេកទេសព្រៃឈើ និងបរិស្ថាន** | ៦ |
| | - គោលបំណងនៃផែនការសកម្មភាព ៤ ឆ្នាំ របស់ក្រុមការងារបច្ចេកទេសព្រៃឈើ និង បរិស្ថាន | ៧ |
| | - ការអភិវឌ្ឍន៍ផែនការសកម្មភាពរបស់ក្រុមការងារបច្ចេកទេសព្រៃឈើ និង បរិស្ថាន | ៨ |
| ២ | **ការពិនិត្យឡើងវិញ លើគោលនយោបាយជាតិ និង អាទិភាពនានា ក្នុងវិស័យព្រៃឈើ** | ៩ |
| | - កំណែទំរង់សំខាន់ៗក្នុងវិស័យព្រៃឈើ និងការអភិរក្សធម្មជាតិ | ៩ |
| | - គោលដៅអភិវឌ្ឍន៍សហវត្សរ៍កម្ពុជា (CMDG) | ៩ |
| | - យុទ្ធសាស្ត្រចតុកោណ សំរាប់ ការរីកចំរើន ឱកាសការងារ សមភាព និង សមត្ថភាពសំរាប់ឆ្នាំ ២០០៣-២០០៨ និងក្របខ័ណ្ឌអនុវត្ត | ១១ |
| | - ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០០៦-២០១០ | ១១ |
| | - ផែនការសកម្មភាពអភិបាលកិច្ច (GAP) | ១២ |
| | - ក្របខ័ណ្ឌយុទ្ធសាស្ត្រសំរាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ | ១៣ |
| ៣ | **សំរង់លទ្ធផលសំខាន់ៗបទសំភាសន៏ជាមួយនឹងអ្នកពាក់ពន្ធ័** | ១៣ |
| ៤ | **ការកំណត់អាទិភាពនានា សំរាប់ដាក់បញ្ចូលក្នុងផែនការ ៤ឆ្នាំ របស់ក្រុមការងារបច្ចេកទេស** | ១៦ |
| | - ទស្សនះស្តីពីការតាមដានត្រួតពិនិត្យ | ២១ |
| | - តារាងៈ ផែនការសកម្មភាពឆ្នាំ២០០៧-២០១០ របស់ក្រុមការងារបច្ចេកទេសព្រៃឈើ និងបរិស្ថាន | |
| | - តារាងៈ ផែនការ និង គំរោងថវិកា ឆ្នាំ២០០៧ | |

## ១. សេចក្តីសង្ខេបនៃក្របខ័ណ្ឌជាយុទ្ធសាស្ត្រសំរាប់ការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងតួនាទីនៃផែនការសកម្មភាពរយៈពេលវែងរបស់ក្រុមការងារបច្ចេកទេសព្រៃឈើ និងបរិស្ថាន

ផ្អែកតាមកិច្ចប្រជុំក្រុមពិគ្រោះយោបល់នៅឆ្នាំ១៩៩៩ ដៃគូទាំងអស់បានចាប់ផ្តើមកិច្ចពិភាក្សាដើម្បីរៀបចំវេទិកា ដោយផ្តោតទៅលើសកម្មភាព និងមូលបទដើម្បីអោយកិច្ចការសម្របសម្រួលជំនួយកាន់តែប្រសើរឡើង។ នៅមុនកិច្ចប្រជុំក្រុមការងារពិគ្រោះយោបល់ក្នុងឆ្នាំ ២០០៤ **សម្តេច ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានប្រកាសរៀបចំរចនាសម្ពន្ធ័ឡើងវិញសម្រាប់ដំណើរការសហប្រតិបត្តិការអភិវឌ្ឍន៍នានា។ គោលការណ៍ជាមូលដ្ឋាននានា រួមមានការបង្កើតឡើងនូវក្រុមការងារបច្ចេកទេសចំនួន ១៨ក្រុម ដើម្បីអភិវឌ្ឍន៍ផែនការ និងសំរបសំរួលការងារ ដែលដឹកនាំដោយរាជរដ្ឋាភិបាលកម្ពុជា សំរាប់រៀបចំរបាយការណ៍ផ្ញើជូនទៅវេទិកាដែលពាក់ពន្ធ័នានា និងគណៈកម្មាធិការសំរបសំរួលរវាងរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ (GDCC)។ GDCC ផ្សារភ្ជាប់ទៅនឹងកិច្ចប្រជុំពិគ្រោះយោបល់ (CG) ចាប់តាំងពីឆ្នាំ ២០០៧ វេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា -CDCF (RGC 2006d)។

អ្វីដែលគេទទួលស្គាល់នោះ គឺយន្តការក្រុមការងារបច្ចេកទេសចំរុះ ពិតជាបានជួយដល់ការអនុវត្តគោលការណ៍ OECD-DAC ហើយក្រោយមកទៀត បានបង្កើតឡើងនូវក្រុមការងារ OECD-DAC ស្តីពីការអនុវត្តរបស់ប្រទេសផ្តល់ជំនួយ និងសេចក្តីប្រកាសទីក្រុងប៉ារីស។ រចនាសម្ព័ន្ធ GDCC/TWG គឺកំពុងអនុវត្តយ៉ាងពេញលេញស្របទៅតាមសេចក្តីណែនាំជាសាកល។ កម្ពុជា និងដៃគូអភិវឌ្ឍន៍ឈានមុខនានាកំពុងតែខិតខំស្វែករកកិច្ចសហប្រតិបត្តិការដំណើរការលឿនមួយដើម្បីការអភិវឌ្ឍន៍ការលើកស្ទួយភាពជាដៃគូពិតប្រាកដ និងទំនួលខុសត្រូវចំពោះគ្នាទៅវិញទៅមក ។

រដ្ឋបាលព្រៃឈើ គឺជាអាជ្ញាធររដ្ឋាភិបាលដែលចំនុះក្រោមក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ មានតួនាទីគ្រប់គ្រងព្រៃឈើនិងធនធានព្រៃឈើស្របទៅតាមគោលនយោបាយព្រៃឈើជាតិ និងច្បាប់ព្រៃឈើ។ ធនធានព្រៃឈើ សំដៅទៅលើការអភិរក្សព្រៃឈើអចិន្ត្រៃយ៍ ដែលរួមមាន ព្រៃផ្តល់ផល ព្រៃការពារ និង និងព្រៃសំរាប់ផ្ទេរ។ នាយកដ្ឋានការពារនិងអភិរក្សធនធានធម្មជាតិ (DNCP) ស្ថិតក្រោមឱវាទក្រសួងបរិស្ថាន មានតួនាទីការពារ និងគ្រប់គ្រងឧទ្យានជាតិ ដោយអនុលោម ទៅតាមព្រះរាជក្រឹត្យ។

កិច្ចការទាំងអស់នេះជាជ្រុងមួយនៃកំណែទម្រង់វិស័យព្រៃឈើ និងជាផ្នែកមួយនៃយុទ្ធសាស្ត្រចតុកោណ និង ជាពិសេសគឺស្ថិតនៅក្រោមដំបូលតែមួយរបស់"ក្រុមការងារTWG-F&E"។ ក្រុមការងារ TWG-F&E ក៏ដូចជាក្រុមការងារបច្ចេកទេសដទៃៗទៀតដែរ នឹងក្លាយទៅជាអង្គភាពប្រតិបត្តិ គោលនយោបាយរបស់រដ្ឋាភិបាលនិងប្រទេសផ្តល់ជំនួយ ការធ្វើផែនការ និងការសំរបសំរួលក្នុងវិស័យព្រៃឈើ។

ក្រុមការងារ TWG-F&E មានតួនាទីសំខាន់ជាអ្នកសម្របសម្រួលនិងគាំទ្រដល់ការផ្តល់ជំនួយអភិវឌ្ឍន៍នានាលើវិស័យព្រៃឈើនិងបរិស្ថាន ដើម្បីធានាថា ធនធានក្នុងស្រុកនិងទទួលបានពីបរទេស ត្រូវបានប្រើប្រាស់ចំទិសដៅនិងប្រកបដោយប្រសិទ្ធភាពសម្រាប់រាជរដ្ឋាភិបាលកម្ពុជា។ ក្រុមការងារ TWG-F&E គ្មានបំណងជំនួសអាណត្តិការងាររបស់ក្រសួង ឬអង្គភាពណានោះទេ ប៉ុន្តែគ្រាន់តែសំរបសំរួល ធ្វើផែនការសកម្មភាពណាធំៗដែលជាចំណាប់អារម្មណ៍រួមគ្នាតែប៉ុណ្ណោះ។

## តារាងទី១: គោលបំណងរួមរបស់ក្រុមការងារបច្ចេកទេស

- ពង្រឹងការដឹកនាំ និង ភាពជាម្ចាស់របស់រាជរដ្ឋាភិបាល លើដំណើរការអភិវឌ្ឍន៍តាមរយៈភាពជាដៃគូ។
- បង្កើនការគាំទ្រដល់ដំណើរការអភិវឌ្ឍន៍ក្នុងភាពជាដៃគូស្របទៅតាមយុទ្ធសាស្ត្រគោលនយោបាយ និងអាទិភាពអភិវឌ្ឍន៍ជាតិ។
- ជំរុញភាពជាដៃគូ និង គណនេយ្យភាពទៅវិញទៅមកក្នុងការអភិវឌ្ឍន៍ និង ការអនុវត្តគោលនយោបាយជាតិ និងវិស័យនីមួយៗ យុទ្ធសាស្ត្រ និងផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ស្ដីពីសុខដុមនីយកម្ម ការតំរឹម និងលទ្ធផល។
- ផ្ដល់វេទិកាសំរាប់ពិភាក្សា អំពីការរៀបចំកម្មវិធីក្នុងការប្រើប្រាស់ធនធានក្នុងស្រុក និងជំនួយ ស្របតាមអាទិភាព និង តាមផែនការ ក្នុងលក្ខណៈតម្លាភាព។
- ផ្ដល់ឱកាសក្នុងការត្រួតពិនិត្យ និងវាយតំលៃលើប្រសិទ្ធភាព និងផលប៉ះពាល់ ពីការប្រើប្រាស់ធនធានទាំងអស់ រួមមាន ការត្រួតពិនិត្យឡើងវិញ និងការវិភាគការងារ រួមគ្នា។
- កំណត់ និង យល់ព្រមលើវិធីសាស្ត្រសមស្របណាមួយ សំរាប់ការអភិវឌ្ឍន៍សមត្ថភាព ដែលធ្វើឱ្យប្រសើរឡើងភាពជាម្ចាស់ក្នុងការប្រើប្រាស់ជំនួយបច្ចេកទេស និង ផ្ដល់មធ្យោបាយច្បាស់លាស់ សំរាប់ការវាយតំលៃវឌ្ឍនភាពក្នុងការពង្រឹងសមត្ថភាពរបស់រដ្ឋាភិបាល។
- ការដាក់គណៈកម្មាធិការសំរបសំរួលរវាងរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍នៅចំកណ្ដាលរចនាសម្ព័ន្ធនៃក្រុមបច្ចេកទេស គឺដើម្បីឱ្យការត្រួតពិនិត្យមានប្រសិទ្ធភាពលើយន្តការសំរបសំរួលទាំងមូល និងដើម្បីសិក្សាមេរៀនបទពិសោធន៍ ហើយជំរុញការអនុវត្តរបៀបវារៈប្រសិទ្ធភាពជំនួយសំរាប់

សំរាប់គោលបំណងជាក់លាក់របស់ក្រុមការងារ TWG-F&E សូមមើលឧបសម្ព័ន្ធ ២។

### គោលបំណងនៃផែនការសកម្មភាពរយៈពេល ៤ឆ្នាំ របស់ក្រុមការងារបច្ចេកទេសព្រៃឈើនិងបរិស្ថាន

ដើម្បីរៀបចំផែនការកាន់តែប្រសើរឡើងសំរាប់វិស័យព្រៃឈើ ចាំបាច់ត្រូវតែធ្វើផែនការរយៈពេលវែង។ ផែនការសកម្មភាពរយៈពេល៤ឆ្នាំរបស់ក្រុមការងារ TWG-F&E គឺជាការរួមចំណែកក្នុងការបំពេញទិសដៅនេះ។ ការអភិវឌ្ឍន៍នេះត្រូវតែប្រាកដថា សមាជិកនៃក្រុមការងារ TWG-F&E ត្រូវតាំងចិត្តចូលរួមយ៉ាងសកម្ម ដើម្បីធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍។

ផែនការរយៈពេល៤ឆ្នាំរបស់ក្រុមការងារ TWG-F&E ត្រូវស្របនិងគាំទ្រដល់ការបំពេញតំរូវការជាអាទិភាព គោលនយោបាយជាតិនិងអាទិភាពរួម និងគោលបំណងរួមរបស់ក្រុមការងារ ដូចបានបញ្ជាក់ក្នុងតារាងទី១។ ដូចគ្នានេះ ក្រុមការងារបច្ចេកទេសមិនត្រូវជំនួសតួនាទីរបស់រដ្ឋាភិបាលទេ ប៉ុន្តែគ្រាន់តែជួយបំពេញនូវមុខងារទាំងនោះ។ ទោះជាយ៉ាងណា ផែនការសកម្មភាពរបស់ក្រុមការងារមិនអាចនិងមិនគួរជំនួសការរៀបចំផែនការគ្រប់គ្រងលើធនធានប្រពៃណីបានទេ។ ដូច្នេះ ផែនការសកម្មភាព រយៈពេល ៤ឆ្នាំ របស់ក្រុមការងារ TWG-F&E ចាំបាច់ត្រូវបង្កើតផ្អែកលើ និងឆ្លុះបញ្ចាំង គោលការណ៍ទាំងនេះ។

**តារាងទី២: គោលបំណងនៃផែនការសកម្មភាពរបស់ក្រុមការងារបច្ចេកទេសព្រៃឈើនិងបរិស្ថាន**

| |
|---|
| នេះជាគោលបំណងនៃផែនការ ៤ឆ្នាំ របស់ក្រុមការងារ TWG-F&E ដើម្បីរៀបចំអាទិភាពមួយចំនួន ដែលមានការឯកភាពគ្នាដោយអង្គភាពរបស់រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដើម្បីបុព្វហេតុអភិវឌ្ឍន៍វិស័យព្រៃឈើ និងជួយបំពេញបំណង គោលនយោបាយ និងយុទ្ធសាស្រ្តជាតិ ។ <br> ផែនការនេះនឹងជួយរដ្ឋាភិបាលនិងប្រទេសផ្តល់ជំនួយក្នុងការតឹមថវិកាឱ្យឆ្លើយតបទៅនឹងអាទិភាពទាំងនេះ ក្នុងរយៈពេល៤ឆ្នាំខាងមុខ ហើយជាជំហាននាំទៅដល់ការសំរេចបេសកកម្មរបស់ក្រុមការងារបច្ចេកទេស ដូចដែលរដ្ឋាភិបាលកម្ពុជា រំពឹងទុក ។ |

## ការអភិវឌ្ឍន៍ផែនការសកម្មភាពរបស់ក្រុមការងារបច្ចេកទេសព្រៃឈើនិងបរិស្ថាន

**តារាងទី៣: ការបង្កើតគោលបំណងក្នុងការរៀបចំផែនការរយៈពេល ៤ឆ្នាំ**

| |
|---|
| ១- ជំរុញអោយមានការឯកភាពគ្នាស្តីពីការខិតខំប្រឹងប្រែងនិងបញ្ហាធំៗ ក្នុងផ្នែកនីមួយៗ ។ |
| ២- កំណត់អំពីតំរូវការ និងដំណោះស្រាយ និងជំរុញឱ្យមានការឯកភាពគ្នា ស្តីពីការខិតខំប្រឹងប្រែងក្នុងផ្នែកនីមួយៗ ដើម្បីអភិវឌ្ឍន៍ជាតិ ។ |
| ៣-កំណត់អាទិភាព តើផ្នែកណានិងសកម្មភាពណាដែលត្រូវគាំទ្រ ។ |
| ៤- ផ្សព្វផ្សាយផែនការដើម្បីទទួលយកគំរោងគាំទ្រ ។ |
| ៥- ជំរុញឱ្យមានការយល់ដឹងអំពីការខិតខំប្រឹងប្រែងក្នុងផ្នែកផ្សេងៗ នៅក្នុងរយៈពេល ៤ឆ្នាំទៅមុខនេះ ។ |

កិច្ចសហប្រតិបត្តិការរបស់ក្រុមការងារបច្ចេកទេស ផ្តោតទៅលើអាទិភាពរួមគ្នា ទទ្ទឹមនោះត្រូវដឹងថា ផ្នែកមួយណាដែលដៃគូអភិវឌ្ឍន៍ណាមួយត្រូវទទួលខុសត្រូវបំពេញ ។ ផែនការសកម្មភាពរបស់ក្រុមការងារបច្ចេកទេស គឺត្រូវបំពេញចន្លោះដូចបាន បង្ហាញក្នុងរូបខាងក្រោម ។

**រូបភាពទី១:**



លទ្ធផលនៃក្របខ័ណ្ឌសហប្រតិបត្តិការអភិវឌ្ឍន៍បង្កើតឡើងដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (RGC, 2006a) គឺថា រដ្ឋាភិបាលនិងប្រទេសផ្តល់ជំនួយ និងអ្នកតំណាងផ្សេងៗទៀត ត្រូវមានកិរិតសមត្ថភាពសមស្រប មានសិទ្ធិនិយាយនិងសំរេចជួស មុខអោយអង្គភាពរបស់ខ្លួន ហើយធានាថា បញ្ហាទាំងនេះត្រូវបានចិត្តទុកដាក់ដោះស្រាយក្នុងអង្គភាពរបស់គេ។ ក្នុងករណី ចំណេះដឹងបច្ចេកទេសដែលគេត្រូវការ ហួសពីសមត្ថភាពលេខាធិការដ្ឋានអាចធ្វើបាននោះ ប្រធានក្រុមការងារឬអ្នកសំរបសំរួល ម្ចាស់ជំនួយអាចអញ្ជើញអ្នកជំនាញផ្សេងៗចូលរួមប្រជុំក្រុមការងារបច្ចេកទេសតាមការចាំបាច់។

ដើម្បីធានាឱ្យមាននិរន្តរភាព ភាពជាម្ចាស់ និង ប្រសិទ្ធភាព ល្អនោះ ដំណើរការនៃការរៀបចំផែនការ ៤ឆ្នាំ របស់ក្រុម ការងារ TWG-F&E ត្រូវបានរៀបចំតាមជំហានៈ (១) ពិនិត្យអំពីតំរូវការនាពេលបច្ចុប្បន្ននៅក្នុងវិស័យនីមួយៗ តាមរយៈ ការសំភាសន៍និងពិគ្រោះយោបល់។ (២) ទិសដៅនយោបាយជាតិ ដែលទាក់ទងទៅនឹងវិស័យទាំងពីរ ហើយជាចុងក្រោយ ផ្គូរជា មួយនឹង (៣)អាទិភាពរួមរបស់ដៃគូអភិវឌ្ឍន៍និងសមាជិកក្រុមការងារបច្ចេកទេស។ ផែនការ ៤ឆ្នាំនេះ អនុញ្ញាត្តឱ្យក្រុមតូចៗ រៀបចំសកម្មភាពផ្សេងៗជាក់លាក់ ដើម្បីទទួលនូវអត្ថប្រយោជន៍ជាអតិបរមា។

## ២.ការពិនិត្យឡើងវិញលើគោលនយោបាយជាតិ និងអាទិភាពនានាក្នុងវិស័យព្រៃឈើ

ជាការត្រួសត្រាយផ្លូវ រាជរដ្ឋាភិបាលបានដាក់ចេញនិងប្តេជ្ញាអនុវត្តយុទ្ធសាស្ត្រគោលនយោបាយអភិវឌ្ឍន៍មួយចំនួន។ យុទ្ធសាស្ត្រទាំងនោះ រួមមាន គោលដៅអភិវឌ្ឍន៍សហសវត្សរ៍ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ យុទ្ធសាស្ត្រចតុកោណ ដើម្បី កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ផែនការសកម្មភាពអភិបាលកិច្ច ក្របខ័ណ្ឌយុទ្ធសាស្ត្រសំរាប់សហប្រតិបត្តិការអភិវឌ្ឍន៍ និង យុទ្ធសាស្ត្រជាតិដើម្បីកាត់បន្ថយភាពក្រីក្រ ។

ជាងនេះទៅទៀតរាជរដ្ឋាភិបាលកម្ពុជាបានរៀបចំកំណែទំរង់មួយចំនួន ក្នុងនោះមាន កំណែទំរង់ច្បាប់និងប្រព័ន្ធយុត្តិ ធម៌ កំណែទំរង់រដ្ឋបាលសាធារណៈ កំណែទំរង់វិស័យព្រៃឈើ កំណែទំរង់វិស័យនេសាទ និងជលផល និងកំណែទំរង់ដីធ្លី និង បោសសំអាតមីន និងកំណែទំរង់កងកំលាំងប្រដាប់អាវុធ។

### កំណែទំរង់សំខាន់ៗក្នុងវិស័យព្រៃឈើ

ដើម្បីបង្កើនប្រសិទ្ធភាពការងារ នាពេលថ្មីៗនេះ សេវាកម្មព្រៃឈើរបស់អង្គភាពរដ្ឋាភិបាលបានធ្វើការកែទំរង់រចនា សម្ព័ន្ធរដ្ឋបាល។ កាលពីមុន អង្គភាពព្រៃឈើ មាននាយកដ្ឋានរុក្ខាប្រមាញ់ និងការិយាល័យរុក្ខាប្រមាញ់ខេត្ត-ក្រុង។ អង្គភាព នីមួយៗមានការគ្រប់គ្រងខុសៗគ្នា ដូចជា បណ្តាញបញ្ជានិងរាយការណ៍ គឺទាក់ទងនឹងអភិបាលខេត្ត-ក្រុង។ នៅឆ្នាំ ២០០៣ រចនាសម្ព័ន្ធរដ្ឋបាលត្រូវបានផ្លាស់ប្តូរមកជាបណ្តាញគ្រប់គ្រងរដ្ឋបាលខ្សែបណ្តោយ ពីថ្នាក់កណ្តាលដល់មូលដ្ឋាន។ អង្គភាពតាម លំដាប់ថ្នាក់ដែលមានរដ្ឋបាលគ្រប់គ្រងខ្សែបណ្តោយនិងមានលក្ខណៈសហវិមជ្ឈការត្រូវបានបង្កើតឡើង។

### គោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា (CMDG)

អាទិភាពចំបងរបស់ជាតិមានចែងក្នុងទិសដៅរួម សំរាប់ការអភិវឌ្ឍជាតិ ដើម្បីសំរេចគោលដៅក្នុងឆ្នាំ ២០១៥។

រាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញាចិត្ត សំរេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សហវត្សរ៍កម្ពុជា ដែលជាមូលដ្ឋានយុទ្ធសាស្ត្រ និង គោលនយោបាយអភិវឌ្ឍកម្ពុជា។ របាយការណ៍ CMDG គឺជាឯកសារបញ្ជាក់អំពីការប្តេជ្ញាចិត្តមោះមុតរបស់កម្ពុជាក្នុងការ អនុវត្ត។ របាយការណ៍នេះបានពិពណ៌នាអំពីស្ថានភាពធនធានធម្មជាតិ និងការយល់ស្របគ្នាថា ការធ្វើឱ្យប្រសើរឡើងនូវការ គ្រប់គ្រងធនធានធម្មជាតិ ពិតជារួមចំណែកដល់ការអភិវឌ្ឍន៍តំបន់ជនបទ និងការកាត់បន្ថយភាពក្រីក្រ។ ទោះជាយ៉ាងណា ធនធានធម្មជាតិកំពុងតែរេចរឹលក្នុងកិរិតមួយគួរឱ្យព្រួយបារម្ភ។ គំរបព្រៃឈើបានបាត់បង់ចំនួន ២លាន ហិកតា ស្មើនឹង០.៥%

ក្នុងមួយឆ្នាំ ចាប់តាំងពីឆ្នាំ ១៩៦០ ដល់២០០២ (RGC, 2003a)។ អត្រានេះ បញ្ជាក់ថា កម្ពុជានឹងមិនអាចសំរេចគោលដៅអភិវឌ្ឍន៏សហសវត្សរ៍ ក្នុងឆ្នាំ ២០១៥ បានទេ ប្រសិនបើមិនបានចាត់វិធានការប្រកបដោយប្រសិទ្ធភាពទេនោះ។

ពាក់ព័ន្ធជាមួយវិស័យព្រៃឈើ ក្នុង CMDG ទី១ គឺ "ការលុបបំបាត់នូវភាពអត់ឃ្លាននិងភាពក្រីក្រ" និង CMDG ទី៧ គឺ "ការធានាឱ្យមានចិរភាពបរិស្ថាន" គឺជាចំនុចចាប់អារម្មណ៏។

កត្តាសំរេចជោគជ័យ CMDG ទី១ "ការលុបបំបាត់នូវភាពអត់ឃ្លាននិងភាពក្រីក្រ" គឺទាក់ទងនឹងការអភិវឌ្ឍន៏ វិស័យព្រៃឈើ។ ក្នុងស្ថានភាពប្រទេសកម្ពុជាដែលមានប្រជាជន ៩០% រស់នៅជនបទ និងមានផ្ទៃដីប្រមាណជា ៦០%គ្របដណ្តប់ដោយព្រៃឈើ។ ឯកសារផ្លូវការបញ្ជាក់ថា "ព្រៃឈើគឺជាធនធានធម្មជាតិដ៏សំខាន់បំផុត របស់កម្ពុជាសំរាប់ការអភិវឌ្ឍន៏ប្រទេស ..." (RGC.GAP.p.22)

កត្តាសំរេចជោគជ័យ CMDG ទី ៧ "ការធានាឱ្យមានចិរភាពបរិស្ថាន" គឺផ្តែកទៅលើការគ្រប់គ្រងព្រៃឈើ និងគោលដៅរួម នោះគឺការធ្វើសមាហរណកម្មគោលការណ៏អភិវឌ្ឍន៏ប្រកបដោយចិរភាពទៅក្នុងគោលនយោបាយជាតិ និងក្នុងកម្មវិធីដើម្បីទប់ស្កាត់ភាពរេចរឹលធនធានធម្មជាតិ (RGC, 2003)

ការរៀបចំផែនការសកម្មភាពរយៈពេល ៤ឆ្នាំ របស់ក្រុមការងារ TWG-F&E ឆ្នាំ ២០០៧-២០១០ ចាំបាច់ត្រូវបញ្ជាក់គោលដៅឱ្យបានច្បាស់លាស់ ដែលមានចែងក្នុង CMDG។ ខាងក្រោមនេះ ជាចំនុចដែលទាក់ទងនឹងការរៀបចំផែនការសកម្មភាព ៤ ឆ្នាំ របស់ក្រុមការងារTWG-F&E។

- គោលដៅ ចំណុច ៧.១: ការរក្សាគំរបព្រៃឈើ ៦០% ក្នុងឆ្នាំ ២០០០ ឱ្យបានរហូតដល់ឆ្នាំ ២០១៥។
- គោលដៅ ចំណុច ៧.២: ការរក្សាតំបន់ការពារចំនួន ២៣កន្លែង ក្នុងឆ្នាំ១៩៩៣ ដែលមានផ្ទៃដី ៣.៣ លាន ហិកតាអោយនៅដដែលរហូតដល់ឆ្នាំ ២០១៥។
- គោលដៅ ចំណុច ៧.៣: រក្សាផ្ទៃដីព្រៃការពារថ្មីចំនួន ៦កន្លែង ដែលមានទំហំ ១.៣៥ លានហិកតា ឱ្យបានរហូតដល់ឆ្នាំ ២០១៥។
- គោលដៅ ចំណុច ៧.៥: រក្សាចំនួនអ្នកល្បាតព្រៃ ចំនួន ៥០០នាក់ នៅក្នុងតំបន់ការពារ ឱ្យបានរហូតដល់ឆ្នាំ ២០១៥។ ( RGC 2003a)

របាយការណ៏ CMDG ឆ្នាំ ២០០៣ បានគូសបញ្ជាក់ អំពីសកម្មភាព និងវិធីសាស្រ្តសំខាន់៧ដែលត្រូវយកចិត្តទុកដាក់ក្នុងការរៀបចំ និងកំណត់អាទិភាព មានដូចជា:

- ពង្រឹងការចូលរួមពីសហគមន៏
- បង្កើនការព្យាករណ៏ និងតម្លាភាព ក្នុងការគ្រប់គ្រងធនធាន ជាពិសេស ព្រៃឈើ ទឹក និង សត្វព្រៃ
- ធានាឱ្យមានកិច្ចសហប្រតិបត្តិការក្នុងចំណោមអង្គភាពរដ្ឋាភិបាល
- បញ្ជាក់ឱ្យច្បាស់ពីតួនាទីទទួលខុសត្រូវ និងកិច្ចសំរបសំរួល ក្នុងចំណោម: ១) អង្គភាពរដ្ឋាភិបាល ២) រវាងរដ្ឋាភិបាល និងប្រទេសផ្តល់ជំនួយ ៣) ក្នុងចំណោមប្រទេសផ្តល់ជំនួយ
- កែរលំអសមត្ថភាពស្ថាប័ន និងបច្ចេកទេសរបស់រដ្ឋាភិបាលដើម្បីដោះស្រាយបញ្ហាអន្តរវិស័យ
- ពង្រឹងការអនុវត្តច្បាប់។

## យុទ្ធសាស្ត្រចតុកោណសំរាប់ កំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព ឆ្នាំ ២០០៣-២០០៨ និង ក្របខ័ណ្ឌអនុវត្ត

យុទ្ធសាស្ត្រចតុកោណនេះត្រូវបានបង្កើតឡើង ដែលមានជ្រុងយុទ្ធសាស្ត្រ ៤: ជ្រុងទី១គឺ "ការលើកកំពស់ វិស័យកសិកម្ម "ហើយនៅក្នុងនេះមានកំណែទំរង់វិស័យព្រៃឈើ គឺជាផ្នែកមួយដ៏សំខាន់។ ទាក់ទិនទៅនឹងការរៀបចំផែនការ ភាពជាដៃគូរបស់ក្រុមការងារបច្ចេកទេស នៅក្នុងយុទ្ធសាស្ត្រចតុកោណ យើងពិចារណាលើអាទិភាពចំបង ដូចខាងក្រោម:

ទាក់ទិនទៅនឹងកំណែទំរង់ព្រៃឈើ គឺមាន៣ចំនុច ក្នុងការធានាឱ្យមានការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព (RGC, 2004):

- គោលនយោបាយគ្រប់គ្រងព្រៃឈើប្រកបដោយចិរភាព។
- ប្រព័ន្ធ ការពារធនធានធម្មជាតិ ដើម្បីធ្វើការអភិរក្សជីវៈចំរុះនិងប្រភេទដែលកម្រ
- ការអនុវត្តកម្មវិធីអភិវឌ្ឍន៍សហគមន៍ព្រៃឈើ

## ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០០៦-២០១០

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(NSDP) ឆ្នាំ ២០០៦-២០១០ គឺជាផែនការជាតិ សំរាប់ការរៀបចំនយោបាយ និងការអនុវត្ត ដើម្បីសំរេចបាននូវគោលដៅជាក់លាក់មួយចំនួនត្រឹមឆ្នាំ ២០១០។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ត្រូវបានសំយោគ និងបញ្ចូលអាទិភាពខ្លះនៃផែនការយុទ្ធសាស្ត្រពីមុន ដូចជា: យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ និងផែនការអភិវឌ្ឍសេដ្ឋកិច្ចសង្គមទី ២។ បន្ថែមលើនេះ ផែនការនេះបានតម្រឹមយុទ្ធសាស្ត្រតាមវិស័យនិងវដ្តនៃការធ្វើផែនការទៅជាប្រពន្ធ័សរុបរួមមួយ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ត្រូវបានបង្កើតឡើងតាមរយៈការប្រឹក្សាយោបល់ជារួមជាមួយក្រសួងនានា និងក្រុមការងារបច្ចេកទេសផ្សេងៗ។

អាទិភាព ខាងក្រោមនេះត្រូវបានគេដកស្រង់ សំរាប់រៀបចំផែនការក្រុមការងារបច្ចេកទេសព្រៃឈើនិងបរិស្ថាន។ ដូចគ្នាទៅនឹងយុទ្ធសាស្ត្រចតុកោណដែរ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ផ្អែកលើ ៣ចំនុច:

- គោលនយោបាយគ្រប់គ្រងព្រៃឈើប្រកបដោយចិរភាព។
- ប្រព័ន្ធ ការពារធនធានធម្មជាតិ ដើម្បីធ្វើការអភិរក្សជីវៈចំរុះនិងប្រភេទដែលកម្រ
- ការអនុវត្តកម្មវិធីអភិវឌ្ឍន៍សហគមន៍ព្រៃឈើ

ជាពិសេស ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជាកំពុងខិតខំប្រឹងប្រែងយ៉ាងខ្លាំងដើម្បីអនុវត្តកម្មវិធីព្រៃឈើជាតិ ដោយផ្តោតលើអាទិភាព ដូចខាងក្រោម:

- ផ្តោតលើការកែទំរង់វិស័យព្រៃឈើ
    - o ពង្រឹងការអភិរក្សនិងគ្រប់គ្រងព្រៃឈើ
    - o ជំរុញការគ្រប់គ្រងព្រៃឈើឱ្យចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម
    - o ជំរុញការគ្រប់គ្រងព្រៃឈើឱ្យចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ
    - o ជំរុញការដាំឈើ ដើម្បីជំនួសតំរូវការទាំងស្រុងពីព្រៃឈើធម្មជាតិ
    - o បង្កើនចំណេះដឹងដល់សាធារណៈជន ក្នុងការដាំដើមឈើឡើងវិញ និងចេះប្រើប្រាស់ចំការឈើសហគមន៍ សំរាប់បំពេញតំរូវការ អុស និងធ្យូង។

## ផែនការសកម្មភាពអភិបាលកិច្ច

អាទិភាពសំខាន់ជាងគេ នៅក្នុងផែនការសកម្មភាពអភិបាលកិច្ច គឺការស្គាល់គោលការណ៍មួយ "អភិបាលកិច្ចល្អ គឺ ភាពជាដៃគូប្រកបដោយប្រសិទ្ធិភាពនិងតម្លាភាព ក្នុងចំណោមអ្នកពាក់ពន្ធ័ទាំងអស់"។ ផែនការសកម្មភាពអភិបាលកិច្ចបញ្ជាក់ថា រដ្ឋាភិបាលនឹងបន្តសកម្មភាពរបស់ខ្លួនឱ្យកាន់តែមានតម្លាភាពនិងច្បាស់លាស់ និង តាមវិធីដែលមានលក្ខណៈជាប្រពន្ធ័ថែមទៀត។

ផែនការសកម្មភាអភិបាលកិច្ច ផ្តោតលើចំនុចសំខាន់ចំនួន ៣ គឺៈ ទី១- សមត្ថភាពរបស់អង្គភាពក្នុងការសំរបសំរួល និងគ្រប់គ្រង។ ទី២- ធានាអោយមានការខិតខំប្រឹងប្រែងរបស់ក្រសួង និងដៃគូអភិវឌ្ឍន៍ ក្នុងការគាំទ្រដល់តំរូវការអភិវឌ្ឍន៍សមត្ថភាព។ ទី៣- អនុវត្តនូវកម្មវិធីអភិវឌ្ឍន៍ស្ថាប័ន។ ផែនការ ៤ឆ្នាំ របស់ក្រុមការងារបច្ចេកទេស សុទ្ធតែបានបញ្ចូលរាល់ចំនុចទាំងអស់នេះ។

លើសពីនេះទៀត ផែនការសកម្មភាពអភិបាលកិច្ច ក៏បានរៀបចំនូវសកម្មភាពអភិបាលកិច្ច ដូចជាការរៀបចំក្រិត្យអំពីការគ្រប់គ្រងព្រៃសម្បទាន ច្បាប់ព្រៃឈើ អនុក្រិត្យស្តីពីព្រៃឈើសហគមន៍។ល។ ច្បាប់ទាំងនេះសុទ្ធតែត្រូវបានអនុមត័រួចហើយ។ ជាងនេះទៀត ផែនការនេះក៏បានបញ្ជាក់ផងដែរថា វិស័យព្រៃឈើនឹងរៀបចំក្របខ័ណ្ឌទូទៅមួយ សំរាប់ការអភិវឌ្ឍន៍វិស័យព្រៃឈើដែលកំពុងទទួលបាននូវការចាប់អារម្មណ៍ជាពិសេស។ គួរកត់សំគាល់ថា ជាទូទៅ លទ្ធផលរំពឹងទុកទាំងនេះនឹងមិនអាចសំរេចបានលទ្ធផលវិជ្ជមានបានដូចពោលក្នុងផែនការសកម្មភាពអភិបាលកិច្ចនោះឡើយ។ ឧទាហរណ៍ ទាក់ទងនឹង ការកាប់ព្រៃឈើខុសច្បាប់ តម្លាភាព និងប្រាក់ចំណូលនៅក្នុងវិស័យទាំងពីរនេះ បើសិនលក្ខខណ្ឌសំរាប់សំរេចជោគជ័យនេះមិនទាន់បានបំពេញ ដូចជា ការផ្តល់ប្រាក់បៀវត្សរ៍គ្រប់គ្រាន់ដល់បុគ្គលិកដែលគ្រប់គ្រងធនធានធម្មជាតិ។ បច្ចុប្បន្ននេះ ក្របខ័ណ្ឌកម្មវិធីព្រៃឈើជាតិ គឺជាជំហានបន្ទាប់ ក្នុងរៀបចំបន្ត។

ទាក់ទងទៅនឹងការគ្រប់គ្រងធនធានធម្មជាតិ មានផ្នែកមួយបានបញ្ជាក់ជាពិសេស នេះគឺជាសំដីដកស្រង់ "ប្រជាជនក្រីក្រមានសិទ្ធិប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងជួយសំរាលភាពក្រីក្រ" ( RGC, GAP P.2)។

ការរៀបចំផែនការសកម្មភាព ៤ឆ្នាំ របស់ក្រុមការងារ TWG-F&E យើងបានពិចារណាអំពីអាទិភាពសំខាន់ៗ ដែលមាននៅក្នុងផែនការសកម្មភាពអភិបាលកិច្ច មានដូចជាៈ

- អភិបាលកិច្ចល្អ គឺភាពជាដៃគូប្រកបដោយប្រសិទ្ធិភាពនិងតម្លាភាព ក្នុងចំណោមអ្នកពាក់ពន្ធ័ទាំងអស់។
- ផ្តោតទៅលើការបង្កើនសិទ្ធិប្រើប្រាស់ស្របច្បាប់របស់ប្រជាជនក្រីក្រលើធនធានធម្មជាតិ។
- ទទួលខុសត្រូវរួមគ្នាសំរាប់តំរូវការរបស់ស្ថាប័នដែលបានកំណត់រួមគ្នា។
- តំរូវការសំរាប់ក្របខ័ណ្ឌការងារទូទៅមួយសំរាប់វិស័យទាំងអស់។
- ជំរុញភាពជាដៃគូ និងតម្លាភាពក្នុងចំណោមអ្នកពាក់ព័ន្ធនានា។
- ផ្តោតទៅលើការអនុវត្តន៍ច្បាប់និងគោលនយោបាយ។
- ផ្តោតទៅលើការបំបាត់អំពើពុករលួយ (RGC, GAP)។

## ក្របខ័ណ្ឌយុទ្ធសាស្ត្រសំរាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍

"ក្របខណ្ឌយុទ្ធសាស្ត្រសំរាប់ការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ឆ្នាំ ២០០៦" និង "ផែនការសកម្មភាពស្តីពីសុខដុមនីយ៍កម្ម ការតំរឹម និងលទ្ធផល ឆ្នាំ២០០៦" គឺយោងទៅលើក្រុមប្រឹក្សាស្តារនិងអភិវឌ្ឍន៍ ដែលមានអាណត្តិបង្កើនប្រសិទ្ធភាពជំនួយ។ យោងទៅលើ២វិស័យៈ ព្រៃឈើ(រដ្ឋបាលព្រៃឈើ) និងអភិរក្សធម្មជាតិ (នាយកដ្ឋានការពារនិងអភិរក្សធនធាន

ធម្មជាតិ) ហើយជាទូទៅ ការគ្រប់គ្រងធនធាន ត្រូវបានបញ្ជាក់នៅក្នុងសេចក្តីដកស្រង់ខាងក្រោមនេះដែលមាននៅក្នុងផែនការសកម្មភាពស្តីពីសុខដុមនីយ៍កម្ម។ ការអនុវត្តន៍បច្ចុប្បន្ន គឺចូលក្នុង "កិច្ចព្រមព្រៀងមានលក្ខណៈបុគ្គលជាមួយនឹង ក្រសួង និង ទីភ្នាក់ងារផ្តល់ជំនួយ ដោយគ្មានការសំរបសំរួលជាមុនតាមរយៈចំណុចកណ្តាលរបស់រាជរដ្ឋាភិបាល ក្នុងការសំរបសំរួលជំនួយ (ក្រុមប្រឹក្សាស្តារនិងអភិវឌ្ឍន៏កម្ពុជា) គឺជាបញ្ហាធ្ងន់ធ្ងរមួយដែលរារាំងការប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងការសំរបសំរួលជំនួយ (RGC. 2006 a. p.3-4)

**<u>តារាងទី ៤</u>**

| |
|---|
| ក្របខ័ណ្ឌយុទ្ធសាស្រ្តសំរាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៏កម្ពុជាផ្អែកតាមគោលការណ៍ OECD/DAC នៃការអនុវត្តន៍ល្អសំរាប់ការសំរបសំរួលជំនួយ នឹងនាំមកដោយស្វ័យប្រវត្តិនូវការទទួល ស្គាល់យ៉ាងពេញលេញចំពោះយន្តការ TWG/CDCG និងក្រុមការងារបច្ចេកទេសជាចំណុចប្រមូលផ្តុំសំរាប់កិច្ចសហប្រតិបត្តិការ ទូទាំងស្ថាប័ន និង ការធ្វើផែនការ។ ប៉ុន្តែបញ្ហានេះ ស្ថាប័នខ្លះមិនទាន់បានស្គាល់ និងខ្លះទៀតមិនទាន់ឯកភាពទាំងស្រុងនោះទេ។ |

អាទិភាពនិងវិធីសាស្រ្តដែលបានដកស្រង់សំរាប់ការធ្វើផែនការរបស់ក្រុមការងារបច្ចេកទេស គឺមានតិចតួច ប៉ុន្តែមានសារៈសំខាន់:

- ក្រុមការងារបច្ចេកទេស គឺជាច្រកចូល និងជាចំណុចកណ្តាល សំរាប់ការសំរបសំរួលជំនួយនិងធ្វើផែនការ។
- គោលការណ៍ OECD/DAC ជាគោលការណ៍ដែលបានអនុម័តជាផ្លូវការសំរាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៏ ហើយក្រុមការងារបច្ចេកទេសនឹងធានាថា គោលការណ៍ទាំងនេះ ត្រូវបានត្រួតពិនិត្យ។ (RGC 2006a, RGC 2006b)

## ៣. សំរង់លទ្ធផលសំខាន់ៗពីបទសំភាសន៍ជាមួយនឹងអ្នកពាក់ពន្ធ័

ផែនការសកម្មភាពប្រចាំឆ្នាំ ២០០៦ របស់ក្រុមការងារ TWG-F&E ត្រូវបានរៀបចំឡើងផ្អែកលើគោលនយោបាយជារួម (ឯកសារយោង ទំព័រទី ៩) រួមមានវិស័យព្រៃឈើ ការអភិរក្សធម្មជាតិនិងឧទ្យាន ដែលមានការយល់ស្របគ្នាជារួម។ នេះជាឆ្អឹងខ្នងរបស់ផែនការរយៈពេលមធ្យម។

ដើម្បីជំរុញដំណើរការប្រកបដោយការឆ្លុះបញ្ចាំងនិងនិងវិភាគច្បាស់លាស់ ការសំភាសន៏ត្រូវបានរៀបចំឡើងប្រកបដោយមនសិការ ដោយផ្តោតជាសំខាន់ទៅលើលទ្ធផលចុងក្រោយដែលចង់បាន និងផ្តោតតិចតួចទៅលើលទ្ធផលរំពឹងទុក និងធនធានដែលមាន ពោលគឺ សំនួរ និងការពិភាក្សា គឺចាប់ផ្តើម និយាយអំពី ផលប៉ះពាល់ឬតទ្ធិពល(ទាក់ទង នឹងនិរន្តរភាព) បន្ទាប់មកនិយាយអំពី លទ្ធផលជាក់ស្តែង (ប្រសិទ្ធភាព) ផលរំពឹងទុក (ប្រសិទ្ធផល) និងចុងក្រោយ និយាយអំពីធនធាន/មធ្យោបាយ (សកម្មភាព)។ វិធីសាស្រ្តនេះមានលក្ខណៈសមស្របសំរាប់ការធ្វើផែនការរយៈពេលវែងនិងមធ្យម។ ប៉ុន្តែការអនុវត្តន៏វិធីសាស្រ្តនេះ ពិបាកនឹងប្រើទូទៅ ក្នុងការធ្វើសំភាសន៏ជាមួយមនុស្សទាំងអស់។

**រូបភាពទី ២. ដំណើរការនៃការធ្វើបទសំភាសន៍**




អាទិភាពរួមរបស់ក្រុមការងារបច្ចេកទេស

**លទ្ធផលទទួលបានពីការសំភាសន៍ ត្រូវសំយោគតាមផ្នែកនិមួយៗ**

**អភិបាលកិច្ចព្រៃឈើ**

- ការយល់ដឹងអំពី និងការទទួលយក តួនាទីអនាគតរបស់ក្រុមការងារTWG-F&E ជាចំនុចកណ្តាល សំរាប់ ការអភិវឌ្ឍន៍ ការសំរបសំរួលនិងការធ្វើផែនការ គឺហួសពីការស្មានទាំងស្រុង ក្នុងការជួបប្រាស័យជាមួយ ដៃគូ អង្គការក្រៅរដ្ឋាភិបាល (NGO) និងគំរោងផ្សេងៗ។ ចំពោះ NGOs និងអង្គភាពរដ្ឋាភិបាលខ្លះគឺ មិនសូវយល់ដឹងអំពីក្រុមការងារបច្ចេកទេសនេះទេ។
- ស្ថាប័នព្រៃឈើគួរពិចារណាលើ ការអភិវឌ្ឍន៍ ការទំនាក់ទំនង និងបង្ហាញអំពី បេសកកម្ម និងទស្សនៈវិស័យរបស់ខ្លួន។ សំនួរគន្លឹះ មានដូចជា តើព្រៃឈើគឺសំរាប់ធ្វើអ្វី? សំរាប់នរណា? និងហេតុអ្វី? គួរតែសួរឱ្យបានច្បាស់។
- អង្គភាពនិងដៃគូនានា ត្រូវតែពិចារណាបង្កើតផែនការរយៈពេលវែងសំរាប់ កំណត់ទិសដៅ ការធ្វើផែនការ និងអភិបាលកិច្ច។ ផែនការត្រូវតែបង្កើតឡើងដោយពិភាក្សាជាមួយបណ្តាអ្នកពាក់ពន្ធ័ដើម្បីឱ្យមានកិច្ចសហប្រតិបត្តិការប្រក្រតី។
- ដើម្បីធានាឱ្យមាន តម្លាភាព ក្របខ័ណ្ឌយុទ្ធសាស្ត្ររួម និងជាទូទៅ ដើម្បីធានាឱ្យមានលទ្ធភាពព្យាករណ៍ និងវិធីសាស្ត្រទំនាក់ទំនង គឺមានសារៈសំខាន់ណាស់ សំរាប់បង្កើតឡើងនូវបរិយាកាសសហប្រតិបត្តិការ។
- វិស័យនានា និងដៃគូ ចាំបាច់ត្រូវពិនិត្យមើលតួនាទីរបស់ភ្នាក់ងាររដ្ឋាភិបាល មិនមែនពិនិត្យមើលការអនុវត្តនោះទេ តែពិនិត្យមើល ការរៀបចំគោលនយោបាយ បទបញ្ញត្តិ និងក្រមសីលធម៌ និងការតាមដានត្រួតពិនិត្យ។
- ផែនការសកម្មភាពរបស់ក្រុមការងារ TWG-F&E ត្រូវបានផ្តល់អនុសាសន៍ថា ត្រូវមានទំរង់ស្រដៀងគ្នា នឹងផែនការរយៈពេលមួយឆ្នាំ ដែលបានអនុវត្តកាលពីឆ្នាំ២០០៦ កន្លងមកនេះ។ មានគំនិតលើកឡើងស្តីពីការតាមដានត្រួតពិនិត្យ អំពីការអនុវត្តផែនការ៤ឆ្នាំ ឬ១ឆ្នាំ ក្នុងនោះរួមមាន ការត្រួតពិនិត្យប្រចាំឆ្នាំលើសកម្មភាពអនុវត្តផែនការរបស់ក្រុមការងារបច្ចេកទេស ក៏ដូចជាការត្រួតពិនិត្យមើលលើការចល័តថវិកាផងដែរ។
- ឈ្មោះ "**ក្រុមការងារបច្ចេកទេសព្រៃឈើនិងបរិស្ថាន**" ត្រូវបានស្នើឱ្យផ្លាស់ប្តូរទៅជា "**ក្រុមការងារបច្ចេកទេសព្រៃឈើនិងតំបន់ការពារ**" ឬ "**ក្រុមការងារបច្ចេកទេសព្រៃឈើនិងបរិស្ថាន (តំបន់ការពារ)**" ដែលគេយល់ថាជាឈ្មោះមួយសក្តិសមជាង សំរាប់ក្រុមនេះ។

- ច្បាប់ និងការអនុវត្តច្បាប់ (គួបផ្សំផែនការរយៈពេលវែងនិងទូលំទូលាយនោះនឹងបង្កើនស្ថេរភាពដីព្រៃឈើ) ហើយ ដំណើរការតុលាការ ជាបញ្ហាទូទៅ ត្រូវបានលើកឡើងថាទាក់ទងនឹងប្រសិទ្ធភាពការងាររបស់ក្រុមការងារ TWG ។
- ជាទូទៅក្រុមអ្នកផ្តល់ជំនួយចូលចិត្តគាំទ្ររដ្ឋាភិបាល ចំពោះការងារណាដែលមាននៅក្នុងក្រុមការងារបច្ចេកទេសនេះ ។ ភាពស្ទាក់ស្ទើររបស់អ្នកផ្តល់ជំនួយ គឺ អាស្រ័យលើបញ្ហាមួយចំនួន ដែលបានរៀបរាប់ខាងលើ ។

**ការការពារបរិស្ថាន**

- អ្នកគេសំភាសន៍ខ្លះបានបញ្ជាក់ថា ត្រូវតែធ្វើចំណាត់ថ្នាក់តំបន់កាពារឡើងវិញ ហើយការងារនេះជាផ្នែកមួយនៃបេសកកម្មរបស់ក្រុមការងារបច្ចេកទេសនេះ ។
- ក្រុមការងារបច្ចេកទេសនេះ គួរគាំទ្រការគ្រប់គ្រងទិន្ន័យសាធារណៈ និងជុំវិញ ហើយធានាថា រាល់ទិន្នន័យស្រាវជ្រាវអំពីព្រៃឈើ ការអភិរក្ស ត្រូវតែមានសំរាប់សាធារណៈជន ដូចជាទិន្នន័យ ផែនការគ្រប់គ្រង ទិន្នន័យអំពីឡូត៍គំរូអចិន្ត្រៃយ៍ ការសិក្សាអំពីសង្គម និងរុក្ខសាស្ត្រ ផែនការអាជីវកម្មឈើ និងរៀបចំឧទ្យាន ។ល។ នេះក៏រួមបញ្ចូល ទាំងទិន្ន័យនៃគំរូបែបបទរបស់អង្គការ FAO ដូចជា ការតាមដាន ការវាយតំលៃ របាយការណ៍អំពីការគ្រប់គ្រង ព្រៃឈើប្រកបដោយនិរន្តរភាព និង ការវាយតំលៃព្រៃឈើជាសាកល ។
- ត្រូវបង្កើតការគ្រប់គ្រង និងការពារសហគមន៍ ។

**ផលិតកម្មព្រៃឈើ**

- ត្រូវបង្កើតឡើងផ្នែកឯកជន ប៉ុន្តែ មិនតាមរយៈសម្បទានទេ ព្រោះមានក្តីបារម្ភណ៍ច្រើន ។ ជាទូទៅ មានកង្វះខាតព័ត៌មាន និងការវាយតំលៃប្រព័ន្ធគ្រប់គ្រងព្រៃឈើ ទោះបីប្រព័ន្ធទាំងនេះត្រូវអនុវត្តក៏ដោយ ។ ការដាំដើមឈើមានឥទ្ធិពលផ្ទាល់ដល់ការកាត់បន្ថយភាពក្រីក្រ ។
- គេយល់ថា ការអភិរក្សធនធានហ្សែនព្រៃ គឺមានសារៈសំខាន់ណាស់សំរាប់អនាគត និង ផលិតកម្មឈើមានតម្លៃ ទោះជាផលិតកម្មជាលក្ខណៈគ្រួសារ ឬ មានទ្រង់ទ្រាយធំក្តី ។
- ការរៀបចំផែនការ រួមទាំងផែនការរបស់ក្រុមការងារបច្ចេកទេស ត្រូវតែផ្សារភ្ជាប់ជាមួយ គំរោងចំណាយរយៈពេលមធ្យមថ្មី ដើម្បីឱ្យការតាមដានត្រួតពិនិត្យសកម្មភាពមានលក្ខណៈទូលំទូលាយ ។

**ការកសាងសម្ថភាព និង ការចូលរួម**

- គេនិយាយថា ការរៀបចំផែនការរយៈពេលមធ្យមរបស់ក្រុមការងារ TWG-F&E តំរូវឱ្យមាន ក្រុមការងារមួយចំនួន និងពេលវេលាគ្រប់គ្រាន់សំរាប់បំពេញការងារ ។ ការរៀបចំយុទ្ធសាស្ត្រធនធានទឹកនិងកសិកម្ម (ក្រុមការងារបច្ចេកទេសកសិកម្មនិងធនធានទឹកឆ្នាំ ២០០៦) ជាឧទាហរណ៍ ។
- បំណងប្រាថ្នារបស់អ្នកពាក់ពន្ធ័មួយចំនួន ទាំងក្នុងនិងក្រៅក្រុមការងារបច្ចេកទេស ចង់ឃើញការចែករំលែកព័ត៌មានបច្ចេកទេស ឱ្យមានភាពប្រសើរឡើង ។ នេះគឺជាកិច្ចការ ដែលលេខាធិការដ្ឋានក្រុមការងារបច្ចេកទេសអាចធ្វើបាន ។
- ការងារព្រៃឈើសហគមន៍ ដែលបង្កើតដោយអង្គការ OXFAM និងធនធានឋាមពលករកើតឡើងវិញ សំរាប់តំបន់ជនបទ ត្រូវស្នើឡើងថាជាតំបន់អាទិភាព ដើម្បីឱ្យក្រុមការងារបច្ចេកទេសគាំទ្រ ។
- ការកសាងសមត្ថភាពដល់អ្នកពាក់ពន្ធ័ នៅតែមានសារៈសំខាន់ ។ ត្រូវយកចិត្តទុកដាក់ទៅលើលទ្ធផល/ទិន្នផល ។

o ផ្នែកអភិរក្សនិងឧទ្យានត្រូវការជំនួយ ដើម្បីការលើកកំពស់ការយល់ដឹង និងផ្សព្វផ្សាយចំណេះដឹង ។

## ៤_ការកំណត់អាទិភាពនានាសំរាប់ដាក់បញ្ចូលក្នុងផែនការ ៤ឆ្នាំរបស់ក្រុមការងារបច្ចេកទេស

ផែនការ ៤ ឆ្នាំ របស់ក្រុមការងារបច្ចេកទេស គឺផ្អែកលើគោលបំណងនៃគោលនយោបាយ ៤ ដែលបានកំណត់ (សូមមើលទំព័រទី ១៧) ដែលក្លាយជាតំបន់អាទិភាព ហើយមិនប្រឆាំងនឹងកាតព្វកិច្ចអន្តរជាតិនានា ។

បើសិនជាអាច វដ្តនៃការរៀបចំផែនការ គួរតែរឹមឱ្យស្របនឹងយុទ្ធសាស្ត្រជាតិ និងភ្នាក់ងារផ្សេងៗផងដែរ ។ ដូច្នេះ ផែនការរបស់ក្រុមការងារបច្ចេកទេស ត្រូវបានរៀបចំសំរាប់រយៈពេលឆ្នាំ ២០០៦-២០១០ ។ បញ្ហាអន្តរវិស័យ គឺតំរូវឱ្យកិច្ចសហការរវាង នាយកដ្ឋាន និងក្រសួងនានា ឬ ក្រុមការងារបច្ចេកទេសដទៃទៀត ហើយជាទូទៅ ការប្រគល់ទំនួលខុសត្រូវ តែងជួបការលំបាក ។ បញ្ហានេះ ទាមទារការយកចិត្តទុកដាក់ ជាពិសេសពីសំណាក់ប្រធានក្រុមការងារបច្ចេកទេស និង លេខាធិការដ្ឋានក្រុមការងារបច្ចេកទេស ។

ការកំណត់អាទិភាពនានា គឺជាលទ្ធផលនៃការថ្លឹងថ្លែងរវាងកត្តាទាំង ៤ ខាងក្រោមគឺៈ

**តារាងទី៥:**




**តារាងទី ៦: គោលដៅនយោបាយអាទិភាពដែលបានព្រមព្រៀង**

| | |
|---|---|
| *សេចក្តីថ្លែងការណ៍ គោលនយោបាយរួម :*<br>**រាជរដ្ឋាភិបាលកម្ពុជាកំពុងជំរុញការគ្រប់គ្រងនិងអភិរក្សព្រៃឈើប្រកបដោយនិរន្តរភាពដើម្បីជាប្រយោជន៍សេដ្ឋកិច្ចសង្គមដល់ប្រជាជនកម្ពុជា ។** | |
| ១ | *សេចក្តីថ្លែងការណ៍ គោលនយោបាយ និងគោលបំណង:*<br>**ធនធានព្រៃឈើរបស់ប្រទេសត្រូវបានចាត់ទុកជាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ និងត្រូវគ្រប់គ្រងធនធានធម្មជាតិឱ្យមាននិរន្តរភាព ។** |
| | *សមាសភាព អភិវឌ្ឍន៍សំខាន់ៗ:*<br>**ពង្រឹងការគ្រប់គ្រងនិងការអភិរក្សព្រៃឈើ** |
| | *ពាក្យគន្លឹះ :* **អភិបាលកិច្ចព្រៃឈើ** |

| | |
|---|---|
| ២ | *សេចក្តីថ្លែងការណ៍ គោលនយោបាយ និងគោលបំណង:*<br>**ការអភិរក្ស និងការគ្រប់គ្រងប្រកបដោយនិរន្តរភាពនូវធនធានព្រៃឈើជាតិ និង ការដាំព្រៃឈើ ដើម្បីជំនួសតំរូវការប្រើប្រាស់ចេញពីព្រៃធម្មជាតិ ។** |
| | *សមាសភាពអភិវឌ្ឍន៍សំខាន់ៗ:*<br>**ជំរុញការរួមវិភាគទានរបស់ព្រៃឈើ និងការដាំឈើ ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច និង សង្គម ។** |
| | *ពាក្យគន្លឹះ :* **ការអភិរក្ស និង ការដាំព្រៃឈើឡើងវិញ** |
| ៣ | *សេចក្តីថ្លែងការណ៍ គោលនយោបាយ និងគោលបំណង:*<br>**ជីវភាពនៅតំបន់ជនបទ ទទួលបានការគាំទ្រ តាមរយៈការចូលរួមជាអតិបរមាពីសំណាក់ប្រជាជនមូលដ្ឋាន និងការចូលរួមរបស់វិស័យឯកជន ក្នុងការគ្រប់គ្រងធនធានធម្មជាតិ ។** |
| | *សមាសភាពអភិវឌ្ឍន៍សំខាន់ៗ:*<br>**ជំរុញការគ្រប់គ្រងព្រៃឈើឱ្យចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ ។** |
| | *ពាក្យគន្លឹះ :* **ការចូលរួមរបស់សហគមន៍ និង សហគ្រាសព្រៃឈើធុនតូចនិងមធ្យម** |
| ៤ | *សេចក្តីថ្លែងការណ៍ គោលនយោបាយ និងគោលបំណង:*<br>**អនុវត្ត ការចូលរួមរបស់បណ្តាអ្នកពាក់ព័ន្ធផ្សេងៗ ដើម្បីសុខដុមនីយកម្ម ទស្សនៈ ចំណាប់អារម្មណ៍ និង សមត្ថភាពរបស់បណ្តាអ្នកពាក់ពន្ធ័ក្នុងវិស័យព្រៃឈើ ។** |
| | *សមាសភាព អភិវឌ្ឍន៍សំខាន់ៗ:*<br>**ពង្រីកការយល់ដឹងជាសាធារណៈ និងពង្រឹងសមត្ថភាព ក្នុងការប្រើប្រាស់ ធនធានធម្មជាតិប្រកបដោយនិរន្តរភាព ។** |
| | *ពាក្យគន្លឹះ :* **ការអភិវឌ្ឍន៍សមត្ថភាព** |

*សេចក្តីថ្លែងការណ៍អំពី គោលនយោបាយរួម :*

**រាជរដ្ឋាភិបាលកម្ពុជាកំពុងជំរុញការគ្រប់គ្រងនិងអភិរក្សព្រៃឈើប្រកបដោយនិរន្តរភាពដើម្បីជាប្រយោជន៍សេដ្ឋកិច្ចសង្គមដល់ប្រជាជនកម្ពុជា ។**

ព្រៃឈើបានផ្គត់ផ្គង់ការចិញ្ចឹមជីវិតរបស់ប្រជាជននៅជនបទអស់ជាច្រើនសតវត្សរ៍មកហើយ ។ ថ្វីបើជាប្រទេសអភិវឌ្ឍន៍ ក៏ដោយ ការចិញ្ចឹមជីវិតរបស់ប្រជាជន ទោះជាកំពុងរស់នៅក្បែរព្រៃឈើក្តី ឆ្ងាយពីព្រៃក្តី នឹងនៅតែត្រូវការប្រើប្រាស់ផលិត ផល និង សេវាព្រៃឈើ តទៅទៀត ។

ដូច្នេះ សេណារីយោ សំរាប់ការគ្រប់គ្រងនិងអភិរក្សព្រៃឈើត្រូវសម្រួលទៅតាមតំរូវការទាំងនេះ ដោយប្រកាន់ខ្ជាប់ស្របតាមអាទិភាពជាតិ ដើម្បីកាត់បន្ថយភាពក្រីក្រនៅជនបទ ។ ការគ្រប់គ្រងព្រៃឈើ និងឧទ្យាន ស្របតាមគោលការណ៍ទាំងនេះ ក្នុងវិធីមួយប្រកបដោយនិរន្តរភាពនោះ ជាកិច្ចប្រឹងប្រែងមួយនាពេលខាងមុខ ។

សេចក្តីថ្លែងការណ៍អំពីគោលនយោបាយរួមខាងលើ សំដៅលើការអភិវឌ្ឍន៍ប្រកបដោយសមធម៌ដែលមានតុល្យាភាពសង្គមមួយ ឱ្យទន្ទឹមនឹងការរក្សាកំណើនសេដ្ឋកិច្ចជាតិ ។ ដើម្បីសំរេចលទ្ធផលនេះ ការគ្រប់គ្រងត្រូវផ្អែកលើជំនាញបច្ចេកទេស និង ការធ្វើសេចក្តីសំរេចចិត្តត្រូវមានការចូលរួមនិងគោលការណ៍សមធម៌ ជាពិសេសត្រូវផ្តោតជាសំខាន់ទៅលើតំរូវការរបស់ប្រជាជនក្រីក្រ ។ នេះជាមួយគោលដៅអភិវឌ្ឍន៍សំខាន់ពីររបស់កម្ពុជា ដើរឱ្យស្របគ្នា គឺ កំណើនសេដ្ឋកិច្ច និង ការកាត់បន្ថយភាពក្រីក្រ ។

| ១ | *សេចក្តីថ្លែងការណ៍ គោលនយោបាយ និងគោលបំណង:*<br>*ធនធានព្រៃឈើរបស់ប្រទេសត្រូវបានចាត់ទុកជាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ និងត្រូវគ្រប់គ្រងធនធានធម្មជាតិឱ្យមាននិរន្តរភាព ។* |
|---|---|
| | *សមាសភាពអភិវឌ្ឍន៍សំខាន់១:*<br>*ពង្រឹងការគ្រប់គ្រងនិងការអភិរក្សព្រៃឈើ* |
| | *សមាសភាពសម្រាប់ការអភិវឌ្ឍន៍ចាំបាច់ :*<br>**ពង្រឹងការគ្រប់គ្រង និង ការអភិរក្សព្រៃឈើ** |
| | *ពាក្យគន្លឹះ :* **អភិបាលកិច្ចព្រៃឈើ** |

**ផែនការសកម្មភាព រយៈពេលខ្លី និងមធ្យម ( ២០០៧-២០១០ )**

- រៀបចំកម្មវិធីព្រៃឈើ ស្ថិតនៅក្រោមក្របខ័ណ្ឌកម្មវិធីព្រៃឈើជាតិ ដោយផ្សារភ្ជាប់នឹងគោលនយោបាយជាតិ និងរួមទាំងការបញ្ជាក់អំពី គោលដៅបេសកកម្ម និងមធ្យោបាយផ្សេងៗ ។
  - o រៀបចំ និងកំណត់ព្រំប្រទល់ព្រៃឈើជាតិដើម្បីថែរក្សាគំរបព្រៃឈើ ៦០% ។
  - o រៀបចំ និងអនុវត្តផែនការគ្រប់គ្រងព្រៃឈើជាតិ ។
  - o រៀបចំ និងអនុវត្ត កម្មវិធីតូចៗសំរាប់វិស័យព្រៃឈើ ដែលជាសមាសធាតុសំខាន់ៗក្នុងកម្មវិធីព្រៃឈើជាតិ ។
  - o វិភាគប្រសិទ្ធភាពរបបគ្រប់គ្រងព្រៃឈើផ្សេងៗដែលមានសក្តានុពល ។
  - o ពង្រឹងស្ថាប័នស្របតាមតំរូវការដែលមាននៅក្នុង កម្មវិធីព្រៃឈើជាតិ និងការវិភាគអង្គភាព ។
  - o រៀបចំកម្មវិធីវិនិយោគទុនស្របតាមគោលនយោបាយរួម ។
- បញ្ចប់ការវាយតម្លៃគំរបព្រៃឈើជាតិ ។
- អនុវត្តគំរូគ្រប់គ្រងឧទ្យានជាតិ និងរៀបចំផែនការសំរាប់រក្សាតំបន់ការពារ ។
- កំណត់ព្រំប្រទល់តំបន់ការពារឱ្យបានសមស្រប ដោយមានវិធានការដោះស្រាយជម្លោះ ។
- ធ្វើការសាកល្បងគំរូគ្រប់គ្រងព្រៃឈើផ្សេងៗ ។
- បន្ត ការតាមដានត្រួតពិនិត្យ និងរាយការណ៍អំពីបទឧក្រិដ្ឋព្រៃឈើ និងដីធ្លី ។
- បន្តគាំទ្រតួនាទីរបស់ក្រុមការងារTWG-F&E និង ពង្រីកតួនាទីនេះឱ្យស្របតាម យុទ្ធសាស្ត្រជាតិនិងតំរូវចាំបាច់ ដោយធ្វើឱ្យក្រុមការងារបច្ចេកទេស ក្លាយជាចំណុចកណ្តាលមួយ សំរាប់ការ សំរបសំរួលជំនួយនិងរៀបចំផែនការ ។
- គ្រប់គ្រងព្រៃឈើដោយផ្អែកតាម កម្មវិធីព្រៃឈើជាតិ ផែនការរយៈពេលមធ្យម-វែង និងផែនការគ្រប់គ្រងព្រៃឈើរបស់ផ្នែករដ្ឋបាលព្រៃឈើ ។
- ពង្រឹងប្រព័ន្ធកាត់ក្តីនិងតុលាការ សម្រាប់ដោះស្រាយបទឧក្រិដ្ឋដែលពាក់ព័ន្ធព្រៃឈើ និងដីធ្លី ។
- ចាប់ផ្តើមធ្វើសនិទានកម្មនិងចាត់ថ្នាក់ ព្រៃឈើឡើងវិញ បើសិនជាមានថវិកា ។
- ជំរុញអភិបាលកិច្ចល្អក្នុងការគ្រប់គ្រងនិងអភិរក្សព្រៃឈើ តាមរយ:ភាពជាដៃគូជាមួយអ្នកពាក់ពន្ធ័ណាដែលមានប្រសិទ្ធភាព និង តម្លាភាព ។
- បើកចំហគំរោងថវិកា របស់ភាគីដែលពាក់ព័ន្ធក្នុងវិស័យព្រៃឈើនិងបរិស្ថាន ដែលជាតំរូវការព័តិមានសំរាប់ផែនការ និង ការគាំទ្រ ។

- ធានាឱ្យមានតម្លាភាពជាទូទៅ។ គេហទំព័ររបស់ក្រុមការងារ TWG-F&E : www.twgfe.org ជាមធ្យោបាយមួយក្នុងចំណោមមធ្យោបាយជាច្រើន សំរាប់ផ្សព្វផ្សាយព័ត៌មានផ្សេងៗ។

**លទ្ធផលរំពឹងទុក**

ការរៀបចំផែនការរួម និងក្របខ័ណ្ឌគោលនយោបាយរួច គឺបានបញ្ជាក់ច្បាស់លាស់អំពី ទិសដៅ និងបង្ហាញការរីកចំរើននៃការគ្រប់គ្រងនិងអភិរក្សក្នុងវិស័យព្រៃឈើ និងធនធានធម្មជាតិ ហើយនិងវិស័យផ្សេងៗដែលកំពុងផ្តល់អភិបាលកិច្ចធនធានធម្មជាតិបានល្អ។

ប្រតិបត្តិការបំផ្លាញតំបន់ព្រៃឈើត្រូវបានបញ្ចប់ ហើយរាល់ករណីសំនុំរឿងទាំងអស់ ត្រូវបានបញ្ជូនទៅតុលាការ។

ការគ្រប់គ្រងព្រៃឈើល្អដែលចេញពីប្រព័ន្ធនិងរបបគ្រប់គ្រងព្រៃឈើផ្សេងៗ និងបានសំរបតាមស្ថានភាពក្នុងតំបន់។

ការកំណត់ព្រំប្រទល់និងការធ្វើសនិទានព្រៃឈើ បានចាប់ផ្តើមចំពោះសម្បត្តិព្រៃឈើអចិន្រ្តៃយ៍ (រួមទាំងតំបន់ការពារ) រួម ទាំងការផ្តល់ដីព្រៃឈើសំរាប់ របបមុខងារចាំបាច់ និងតំរូវការក្នុងស្រុក និងជម្រើសផ្សេងៗទៀត។

**លក្ខខណ្ឌផ្សេងៗក្នុងការសំរេចជោគជ័យ**

សេវាកម្មស៊ីវិល និងអភិបាលកិច្ចល្អ ទទួលបានអាទិភាពខ្ពស់បំផុត។ ភាពជាដៃគូពិតប្រាកដ និង ការពង្រីកកិច្ចសហប្រតិបត្តិការ ត្រូវបង្កើតឡើង រវាង និងក្នុងចំណោម អ្នកពាក់ពន្ធ័ ហើយនិងរវាងវិស័យផ្សេងៗ។

ត្រូវផ្អែកលើ កិច្ចសហប្រតិបត្តិការល្អប្រសើរ មានប្រសិទ្ធភាពនិងការទុកចិត្តរវាង រដ្ឋាភិបាល សង្គមស៊ីវិល ម្ចាស់ជំនួយ និងដៃគូដទៃទៀត ដែលកំពុងតែគាំទ្រវិស័យទាំងនេះ។

បន្តការរៀបចំផែនការគ្រប់គ្រងឧទ្យានជាតិ និង ការគាំទ្រដល់ការអភិវឌ្ឍន៏វិស័យព្រៃឈើតាមរយៈការរៀបចំកម្មវិធីព្រៃឈើជាតិ។

<table>
<tr><td rowspan="3">២</td><td>សេចក្តីថ្លែងការណ៍ គោលនយោបាយ និងគោលបំណង :<br>ការអភិរក្ស និងការគ្រប់គ្រងប្រកបដោយនិរន្តរភាពនូវធនធានព្រៃឈើជាតិ និង ការដាំព្រៃឈើ ដើម្បីជំនួសតំរូវការប្រើប្រាស់ឈើចេញពីព្រៃធម្មជាតិ។</td></tr>
<tr><td>សមាសភាពអភិវឌ្ឍន៍សំខាន់ៗ:<br>ជំរុញការរួមវិភាគទានរបស់ព្រៃឈើ និងការដាំឈើ ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច និង សង្គម។</td></tr>
<tr><td>ពាក្យគន្លឹះ : ការអភិរក្ស និង ការដាំព្រៃឈើឡើងវិញ</td></tr>
</table>

**ផែនការសកម្មភាព រយៈពេលខ្លី និង មធ្យម ( ២០០៧-២០១០ )**

- សាកល្បងគំរូគ្រប់គ្រងព្រៃឈើក្រោយព្រៃសម្បទាន។
- អនុវត្តកម្មវិធីអភិរក្សហ្សែនព្រៃឈើ រក្សាប្រភពគ្រាប់ពូជនៃប្រភេទឈើក្នុងស្រុក សំរាប់កម្មវិធីដាំឈើ រួមមានការស្តារព្រៃធម្មជាតិឡើងវិញ។
- ដាំឈើឱ្យបានចំនួន ៤០.០០០ ហិចតា រហូតដល់ឆ្នាំ២០១០ សំរាប់ការប្រើប្រាស់ជាប្រយោជន៏សេដ្ឋកិច្ច-សង្គម ដើម្បីជំនួសតំរូវការប្រើប្រាស់ឈើចេញពីព្រៃធម្មជាតិ តាមរយៈការលើកទឹកចិត្តដល់វិនិយោគទុនឯកជន និងការចូលរួមពីសាធារណ:ជន។
- ណែនាំពីគោលការណ៍ និង ការដាំឈើ របស់យន្តការអភិវឌ្ឍន៏ស្អាត (CDM)។

- បង្កើននិរន្តរភាពបរិស្ថាន តាមរយៈការជំរុញសកម្មភាពណាដែលមានផលប៉ះពាល់តិច ដោយមានការសិក្សាអំពី ការវាយតម្លៃផលប៉ះពាល់សង្គមនិងបរិស្ថាន ហើយនិងការអប់រំ រួមមាន ការសាកល្បងប្រពន្ធ័គ្រប់គ្រងព្រៃការពារ ។

**លទ្ធផលរំពឹងទុក**

ការគ្រប់គ្រងប្រកបដោយតម្លាភាព នូវតំបន់ការពារ និង ឧទ្យានជាតិ មានភាពប្រសើរឡើង ។

ការដាំព្រៃឈើឡើងវិញដើម្បីលើកកំពស់ជីវភាពប្រជាជន ការការពារបរិស្ថាន និងផលិតកម្ម មានភាពប្រសើរឡើង ។

របបគ្រប់គ្រងផ្សេងៗដែលមានជោគជ័យនិងសក្តានុពល សំរាប់ព្រៃលុបសម្បទាន ត្រូវបានកំណត់ ហើយការសាកល្បងគ្រប់គ្រងព្រៃលុបសម្បទាន ត្រូវបានចាប់ផ្តើម ។

ការអភិរក្សហ្សែនព្រៃឈើ នូវប្រភេទឈើមានតម្លៃ កំពុងតែអនុវត្ត ។

ការដាំឈើបានយ៉ាងតិច ចំនួន ១០.០០០ ហិចតា ក្នុងមួយឆ្នាំ សំរាប់ជាប្រយោជន៍ដល់ សង្គម និងបរិស្ថាន ។

**លក្ខខណ្ឌផ្សេងៗក្នុងការសំរេចជោគជ័យ**

ត្រូវផ្សព្វផ្សាយការយល់ដឹងស្តីពីទំនាក់ទំនងរវាងបរិស្ថាននិងជីវភាពរស់នៅរបស់ប្រជាជន ហើយការដាំឈើ ត្រូវផ្អែកលើការពិចារណាខាងសេដ្ឋកិច្ច នូវរាល់ទិដ្ឋភាពទាំងអស់ រួមមាន សក្តានុពលសង្គម និង ផលប្រយោជន៍បរិស្ថាន និងចំណាយ ។

| | |
|---|---|
| ៣ | *សេចក្តីថ្លែងការណ៍ គោលនយោបាយ និង គោលបំណង :* **ជីវភាពនៅតំបន់ជនបទ ទទួលបានការគាំទ្រ តាមរយៈការចូលរួមជាអតិបរមាពីសំណាក់ ប្រជាជនមូលដ្ឋាននិងវិស័យឯកជន ក្នុងការគ្រប់គ្រងធនធានធម្មជាតិ ។** |
| | *សមាសភាពអភិវឌ្ឍន៍សំខាន់ៗ :* **ជំរុញការគ្រប់គ្រងព្រៃឈើឱ្យចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ ។** |
| | *ពាក្យគន្លឹះ :* **ការចូលរួមរបស់សហគមន៍ និង សហគ្រាសព្រៃឈើខ្នាតតូចនិងមធ្យម** |

**ផែនការសកម្មភាពរយៈពេលខ្លី និង មធ្យម ( ២០០៧-២០១០ )**

- ពង្រីកការអនុវត្តកម្មវិធីសហគមន៍ព្រៃឈើ ឱ្យបានច្រើនបន្ថែមទៀត ។
- សាកល្បងនិងវាយតម្លៃ ភាពជាដៃគូ និង គំរូចូលរួមគ្រប់គ្រងព្រៃឈើឱ្យបាន១០កន្លែង មានទំហំ ១០.០០០ហិកតា ។
- ទទួលស្គាល់ និងការពារ សិទ្ធិស្របច្បាប់និងសិទ្ធិប្រពៃណីរបស់ប្រជាជនមូលដ្ឋាន ក្នុងការប្រើប្រាស់ធនធានព្រៃឈើ ដើម្បីធានាដល់សន្តិសុខស្បៀង និងការកាត់បន្ថយភាពក្រីក្រ ។
- បង្កើនសេវាកម្មបរិស្ថាន សំរាប់ទេសចរណ៍ធម្មជាតិ នៅតំបន់ណាសមស្រប ។
- សិក្សាតំរូវការឈើ និងប្រភេទឈើ ។
- រៀបចំ និង អនុវត្តកម្មវិធីគ្រប់គ្រងតំបន់ការពារ ដែលមានការចូលរួមរបស់សហគមន៍មូលដ្ឋាន ។

**លទ្ធផលរំពឹងទុក**

បង្កើតបានវេទិកាល្អមួយ សំរាប់ការវិភាគ ការចូលរួម និងការសំរេចចិត្ត ក្នុងការគ្រប់គ្រងព្រៃឈើ ។

សិទ្ធិប្រើប្រាស់ផលិតផលឈើ និងជីវភាពប្រជាជនដែលពឹងផ្អែកលើព្រៃឈើ មានភាពប្រសើរឡើង ។

## **លំនាំខំណាផ្សេងៗក្នុងការសំរេចជោគជ័យ**

មន្ត្រីរដ្ឋបាលព្រៃឈើមូលដ្ឋានត្រូវបំពេញមុខនាទីឱ្យបានល្អ ដោយសហការក្នុងការអភិវឌ្ឍន៍មូលដ្ឋាន ដូចជា ជួយក្នុងការបង្កើតសហគមន៍ព្រៃឈើ និងជួយជ្រុំជ្រែងដល់ប្រជាជនដែលមានជីវភាពពឹងផ្អែកលើព្រៃឈើ ។

ត្រូវបង្កើនការការពារប្រឆាំងនឹងកំលាំងរំលោភចូលតំបន់ព្រៃឈើ ។

| ៤ | *សេចក្តីថ្លែងការណ៍ គោលនយោបាយ និង គោលបំណង :*<br>**អនុវត្ត ការចូលរួមរបស់បណ្តាអ្នកពាក់ព័ន្ធផ្សេងៗ ដើម្បីសុខដុមនីយកម្ម ទស្សនៈ ចំណាប់អារម្មណ៍ និង សមត្ថភាពរបស់បណ្តាអ្នកពាក់ពន្ធ័ក្នុងវិស័យព្រៃឈើ ។** |
|---|---|
| | *សមាសភាពអភិវឌ្ឍន៍សំខាន់ៗ:*<br>**ពង្រីកការយល់ដឹងជាសាធារណៈ និងពង្រឹងសមត្ថភាព ក្នុងការប្រើប្រាស់ ធនធានធម្មជាតិប្រកបដោយនិរន្តរភាព ។** |
| | *ពាក្យគន្លឹះ :* **ការអភិវឌ្ឍន៍សមត្ថភាព** |

## **ផែនការសកម្មភាពរយៈពេលខ្លី និង មធ្យម ( ២០០៧-២០១០ )**

- បន្តការអនុវត្តនូវកម្មវិធីកសាងសមត្ថភាពទូទៅ
- រៀបចំសិក្ខាសាលាសំរាប់ពិភាក្សាបច្ចេកទេស ឬ ប្រធានបទណាមួយជាក់លាក់ នៅក្នុងក្រុមការងារបច្ចេកទេស ។
- អភិវឌ្ឍន៍សមត្ថភាពដល់សហគមន៍ ដើម្បីចូលរួមក្នុងការគ្រប់គ្រងធនធានធម្មជាតិ ។
- ពង្រឹងសមត្ថភាពក្នុងការដោះស្រាយបញ្ហាអន្តរវិស័យ ។
- ផ្សព្វផ្សាយការយល់ដឹងអំពី សិទ្ធិស្របច្បាប់ក្នុងការប្រើប្រាស់ផលិតផលព្រៃឈើ នៅក្នុងព្រៃនិងក្នុងតំបន់ការពារ និងអំពីជំរើសគ្រប់គ្រងរួមគ្នា ដល់ប្រជាជននៅតាមជនបទ ។
- រៀបចំ និងអនុវត្ត កម្មវិធីស្រាវជ្រាវព្រៃឈើ និងសត្វព្រៃ ឱ្យបាននៅចុងឆ្នាំ ២០០៧ ។

## **លទ្ធផលរំពឹងទុក**

សមត្ថភាពរបស់ស្ថាប័ន ត្រូវបានបង្កើន ហើយមានលទ្ធភាព អនុវត្តភាពជាដៃគូ និងអាចផ្តល់សេវាតាមតំរូវការ ។

សមត្ថភាពចូលរួមរបស់ប្រជាជននៅជនបទក្នុងការគ្រប់គ្រងព្រៃឈើនិងឧទ្យានជាតិ ត្រូវបានបង្កើន ។

## **លំនាំខំណាផ្សេងៗក្នុងការសំរេចជោគជ័យ**

ការកសាងសមត្ថភាព និង ការពង្រឹងស្ថាប័ននោះ មានមិនត្រឹមតែវគ្គបណ្តុះបណ្តាល និង លទ្ធផលសិក្ខាសាលា ប៉ុណ្ណោះទេ តែត្រូវគិតអំពីប្រសិទ្ធភាពនិងឥទ្ធិពលរបស់វានាអនាគត ដូចជាកំណើននៃ ទេពកោសល្យ ចំណេះដឹង និងអាកប្បកិរិយា ដែលគេប្រើប្រាស់ក្នុងការងារប្រចាំថ្ងៃ ទើបចាត់ទុកថាលទ្ធផលពិត( ប្រសិទ្ធភាព) នៃការកសាងសមត្ថភាព ។

## **ទស្សនៈស្តីពីការតាមដានត្រួតពិនិត្យ**

មិនចោទជាបញ្ហាទេ ថាតើ ផែនការ ៤ឆ្នាំ របស់ក្រុមការងារ TWG-F&E រៀបចំបានល្អយ៉ាងណាទេ តែការអនុវត្តជានិច្ចកាល ត្រូវតែពិនិត្យនូវមេរៀនបណ្តើរៗ ហើយត្រូវផ្លាស់ប្តូរតាមកាលៈទេសៈ នេះហើយជាការតាមដានត្រួតពិនិត្យ ក្នុងការទទួលនូវមេរៀនល្អៗ និង ការឆ្លុះបញ្ចាំងអំពីលទ្ធផលផ្សេងៗ ។

ផែនការ ៤ឆ្នាំ របស់ក្រុមការងារ TWG-F&E មិនអាចប្រៀបធៀបជាមួយគំរោងដែលមានថវិកាគាំទ្ររួចហើយនោះទេ ព្រោះថាគំរោងនេះ គេអាចត្រួតពិនិត្យបាន ទៅលើ ធនធាន ប្រសិទ្ធភាព ប្រសិទ្ធផល ផលប៉ះពាល់ និរន្តរភាព និងការជាប់ពាក់ពន្ធ័ផ្សេងៗទៀត។ ផែនការ ៤ឆ្នាំ និងប្រចាំឆ្នាំ របស់ក្រុមការងារ TWG-F&E ត្រូវការវិធីផ្សេងក្នុងការតាមដានត្រួតពិនិត្យ និងវាយតម្លៃ (GDCC បានដាក់រួចទៅហើយ នូវស្ទ័យត្រួតពិនិត្យ និងទំរង់ប្រព័ន្ធរាយការណ៍)។ បើសិនជាមាន មូលនិធិបន្ថែមចូលទៅក្នុងប្រពន្ធ័/ច្រកក្រុមការងារបច្ចេកទេស នោះផែនការប្រចាំឆ្នាំរបស់ក្រុមការងារបច្ចេកទេស ត្រូវមានប្រពន្ធ័វាយតម្លៃដោយឡែក( មិនទាន់បានរៀបចំទេ)។

ចំពោះផែនការ៤ឆ្នាំរបស់ក្រុមការងារ TWG-F&E វិញ មានអនុសាសន៏ឱ្យពិចារណាលើការត្រួតពិនិត្យ នៅត្រឹមកំរិតកម្មវិធី រួមមាន :

- o ទិសដៅរបស់ ផែនការសកម្មភាព ៤ឆ្នាំ របស់ក្រុមការងារបច្ចេកទេស។
- o លទ្ធផលរបស់ផែនការសកម្មភាព ៤ឆ្នាំ របស់ក្រុមការងារបច្ចេកទេស។
- o ចំណុចគោល និងចំណុចដៅ (ផែនការប្រចាំឆ្នាំ មានសូចនាករជាក់លាក់សំរាប់ការត្រួតពិនិត្យ)។
- o សកម្មភាពហិរញ្ញវត្ថុ (កំណើនមូលនិធិ)

***ការត្រួតពិនិត្យទិសដៅរបស់ផែនការសកម្មភាព ៤ឆ្នាំ របស់ក្រុមការងារបច្ចេកទេស:*** ថាតើមាតិការបស់ផែនការនេះស្របទៅនឹង អាទិភាពនានានៃរបៀបវារៈនយោបាយរបស់ កម្ពុជានិងដៃគូអភិវឌ្ឍន៍ដែរឬទេ។ នេះជាការត្រួតពិនិត្យមិនចេះចប់លើសកម្មភាពកំពុងដំណើរការ ក៏ដូចជាការចង្អុលបង្ហាញសំរាប់សកម្មភាពនាអនាគត ហើយបង្កើតសកម្មភាពតាមកំរិតណាមួយឱ្យសមស្របនឹងបច្ចុប្បន្នកាល។

***ការត្រួតពិនិត្យលទ្ធផលនៃផែនការសកម្មភាព ៤ឆ្នាំ របស់ក្រុមការងារបច្ចេកទេស:*** ថាតើ កម្មវិធីឬផែនការទទួលលទ្ធផលសមនឹងថវិកាឬទេ។ ជាក់ស្តែង លទ្ធផលរបស់ផែនការ អាស្រ័យទៅលើលទ្ធផលរបស់សកម្មភាពនីមួយៗ។ ក៏ប៉ុន្តែ នៅក្នុងបរិបទត្រួតពិនិត្យ មិនមានទំនាក់ទំនងសាមញ្ញឡើយ រវាងលទ្ធផលរបស់សកម្មភាព និងលទ្ធផលរបស់ផែនការសរុប។ ហេតុផលមួយគឺថា សកម្មភាពមានចរឹកមួយដាច់ដោយឡែក ហើយជារឿយៗ មិនមានខ្លឹមសារអ្វី ក្នុងការបន្ថែមពួកវា ចូលទៅក្នុងការវាយតម្លៃលទ្ធផលនោះឡើយ។ ដូច្នេះ គំរូវឱ្យធ្វើការវិភាគលំអិតបន្ថែមទៀត ទៅលើផ្នែកធំៗនៃលទ្ធផល/ផលរំពឹងទុក រួមមាន: ការសិក្សាអំពីផែនការនិងកត្តាខាងក្រៅដែលប្រហែលជារួមចំណែកក្នុងការសំរេចលទ្ធផល( ការរៀបចំប្រព័ន្ធត្រួតពិនិត្យបែបនេះប្រហែលជាមានប្រយោជន៏ដល់ក្រុមការងារបច្ចេកទេស)។

***ការត្រួតពិនិត្យចំណុចដៅ:*** ទៅតាមលទ្ធភាព សកម្មភាពនីមួយៗក្នុងផែនការ៤ឆ្នាំ របស់ក្រុមការងារ TWG ត្រូវបញ្ជាក់អំពីសូចនាករ។ ដូច្នេះ បើអាចធ្វើទៅបាន គួរបញ្ជាក់អំពី ពេលវេលានិងចំណុចសំរេចគោលដៅ ដើម្បីងាយធ្វើការតាមដាន និងត្រួតពិនិត្យ។ ចំនុចខ្សោយក្នុងការប្រើវិធីសាស្ត្រនេះតែឯង គឺថា លទ្ធភាពក្នុងការវាស់សូចនាករមួយចំនួន និងការស្វែងយល់ស៊ីជំរៅអំពីស្ថានភាពអនុវត្ត នៅមានកំរិត។

***ការត្រួតពិនិត្យសកម្មភាពហិរញ្ញវត្ថុ (កំណើនមូលនិធិ):*** ការត្រួតពិនិត្យចំណុចដៅ ថាតើមូលនិធិប៉ុន្មានត្រូវបានប្រើប្រាស់ និងសំរាប់គោលបំណងមួយណា ដោយប្រៀបធៀបនឹងគំរោងថវិកាប្រចាំឆ្នាំ។ វិធីសាស្ត្រនេះ គំរូវមានការបើកចំហរព័ត៌មាន អំពីមូលនិធិទាំងអស់ ដែលផ្តល់ឱ្យវិស័យផ្សេងៗ។

# ឯកសារយោង


Danida/ DFID, ២០០៦: កម្មវិធីគ្រប់គ្រងធនធានធម្មជាតិនិងជីវភាពប្រជាជន (២០០៦-២០១០)

RGC ២០០២: យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ឆ្នាំ២០០២

RGC. ២០០២.ខ: ច្បាប់ស្តីពីព្រៃឈើ ឆ្នាំ២០០២

RGC. ២០០២.គ: សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីគោលនយោបាយព្រៃឈើជាតិ

RGC.២០០៣.ក: របាយការណ៍គោលដៅសហស្សវត្សរ៍កម្ពុជា

RGC.២០០៣.ខ: យុទ្ធសាស្ត្រចតុកោណ ដើម្បី វឌ្ឍនភាព ការងារ សមធម៌ ប្រសិទ្ធភាព (២០០៣-២០០៨)

RGC. ២០០៤: ការអនុវត្តយុទ្ធសាស្ត្រចតុកោណ និង តម្រូវការជំនួយអភិវឌ្ឍន៍

RGC. GAP : ផែនការសកម្មភាពអភិបាលកិច្ច

RGC. ២០០៦.ក: ក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងសហប្រតិបត្តិការអភិវឌ្ឍន៍

RGC. ២០០៦.ខ: ផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល

RGC. ២០០៦.គ: ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០០៦-២០១០

RGC. ២០០៦.ឃ: ការពិនិត្យឡើងវិញលើយន្តការ គណៈកម្មាធិការសម្របសម្រួលរវាងរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ និងក្រុមការងារបច្ចេកទេស ។

TWG កសិកម្ម និង ទឹក ២០០៦ យុទ្ធសាស្ត្រធនធានទឹក និង កសិកម្ម (២០០៦-២០១០)

WB. ២០០៦ កម្ពុជា: តើនៅមានភាពក្រីក្រទៀតទេ ក្នុងឆ្នាំ ២០១៥? ការវាយតម្លៃភាពក្រីក្រ ឆ្នាំ ២០០៦


សំគាល់:

RGC : Royal Government of Cambodia: រាជរដ្ឋាភិបាលកម្ពុជា

GAP: Governance Action Plan

WB: World Bank

## ផែនការសកម្មភាពឆ្នាំ ២០០៧_២០១០ របស់ក្រុមការងារបច្ចេកទេសព្រៃឈើនិងបរិស្ថាន

(យោងតាម ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០០៦-២០១០ (NSDP)

| | | | | | | | |
|---|---|---|---|---|---|---|---|
| **សេចក្តីថ្លែងការណ៍គោលនយោបាយរួមៈ រាជរដ្ឋាភិបាលកំពុងជំរុញការគ្រប់គ្រងនិងការអភិរក្សព្រៃឈើប្រកបដោយនិរន្តរភាពដើម្បីជាប្រយោជន៍សេដ្ឋកិច្ចសង្គមដល់ប្រជាជនកម្ពុជា** | | | | | | | |
| **គោលបំណងទី ១** | **ធនធានព្រៃឈើរបស់ប្រទេសត្រូវបានចាត់ទុកជាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ និង ការគ្រប់គ្រងធនធានធម្មជាតិមាននិរន្តរភាពចីរភាព។** | | | | | | |
| សមាសធាតុអភិវឌ្ឍន៍សំខាន់ៗ | **ពង្រឹងការគ្រប់គ្រង និងការអភិរក្ស ព្រៃឈើ**<br>*ពាក្យគន្លឹះ :* **អភិបាលកិច្ចព្រៃឈើ** | | | | | | |
| **លទ្ធផលរំពឹងទុក** | **សកម្មភាព** | **សូចនាករ/ ការផ្ទៀងផ្ទាត់** | **គម្រោងពិភាក្សា** | | | | **ស្ថាប័នអនុវត្ត** |
| | | | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | |
| ១.១ ក្របខ័ណ្ឌយុទ្ធសាស្ត្ររួមមួយសំរាប់វិស័យព្រៃឈើៈ កម្មវិធីព្រៃឈើជាតិ ដើម្បីបង្កើនតម្លាភាព ការបញ្ជាក់នឹងបង្ហាញច្បាស់អំពីទិសដៅ និងសហប្រតិបត្តិការរវាងអ្នកពាក់ពន្ធ័ ហើយអនុលោមតាមយុទ្ធសាស្ត្រជាតិសំរាប់ការអភិវឌ្ឍន៏ | ១.១.១ សំរបសំរួលក្របខណ្ឌ័ផែនការរួមគ្នា ក្នុងការរៀបចំផែនការថ្នាក់ជាតិ និងកម្មវិធីព្រៃឈើជាតិ។ | របាយការណ៏សេចក្តីថ្លែងការណ៍អំពីបេសកកម្ម និង ផែនការ | ●—● | | | | FA/DNCP |
| | ១.១.២ រៀបចំ និងកំណត់ព្រំប្រទល់ព្រៃឈើជាតិដើម្បីរក្សាគំរបព្រៃ ៦០% ។ | ផែនការត្រូវបានផ្សាយជាសាធារណៈ | ●— | —● | | | FA |
| | ១.១.៣ រៀបចំនិងអនុវត្តកម្មវិធីតូចៗសំរាប់វិស័យព្រៃឈើ ដែលជាសមាសធាតុក្នុងកម្មវិធីព្រៃឈើជាតិ។ | មានកម្មវិធីតូចៗត្រូវបានផ្សាយជាសាធារណៈ | ●— | —● | | | FA |
| | ១.១.៤ រៀបចំ និងអនុវត្តផែនការគ្រប់គ្រងព្រៃឈើជាតិ។ | ផែនការតូច-ធំត្រូវផ្សាយជាសាធារណៈ | | ●—▶ | | | FA |
| | ១.១.៥ វិភាគប្រសិទ្ធភាពរបបគ្រប់គ្រងព្រៃឈើផ្សេងៗដែលមានសក្តានុពល។ | របាយកាណ៏នៃការវិភាគ | ●—● | | | | FA |
| | ១.១.៦ ពង្រឹងស្ថាប័នស្របតាមតំរូវការដែលមាននៅក្នុងកម្មវិធីព្រៃឈើជាតិ និងការវិភាគអង្គភាព។ | របាយការណ៏នៃការវិភាគ និងការសន្យាផ្តល់មូលនិធិ សំរាប់ការពង្រឹងស្ថាប័ន | ●—● | ●— | —— | ▶ | FA/TWG |
| | ១.១.៧ រៀបចំកម្មវិធីវិនិយោគស្របតាមគោលនយោបាយរួម។ | កម្មវិធីវិនិយោគទុន | | ●— | —● | | FA |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ១.១.៨ បើកចំហព័ត៌មានស្តីពីថវិការបស់ភាគីពាក់ព័ន្ធក្នុងវិស័យ ផ្សេងៗ ដែលជាតំរូវការ សំរាប់រៀបចំផែនការ និងការគាំទ្រ ។ | ព័ត៌មានស្តីពីគំរោងថវិកា | ● | ─ | ─ | ─▶ | FA/DNCP |
| ១.២ ការគ្រប់គ្រងទិន្នន័យ និងពត៌មាន ដែលអាចប្រើប្រាស់សំរាប់ការគ្រប់គ្រងព្រៃឈើ និងការត្រួតពិនិត្យ ។ | ១.២.១ បញ្ចប់ការវាយតំលៃគំរបព្រៃឈើជាតិ ឆ្នាំ២០០៦ | ផែនទី និង ទិន្នន័យ ឌីជីថល | ●● | | | | FA |
| | ១.២.២ កំណត់ព្រំប្រទល់តំបន់ការពារនិងមានវិធានការដោះស្រាយជំលោះ ។ | ផែនទី បញ្ជីឈ្មោះតំបន់ការពារដែលបានកំណត់ព្រំ ប្រទល់ និងផែនការគ្រប់គ្រង ។ | ● | ─ | ─▶ | | DNCP |
| | ១.២.៣ ធ្វើការសាកល្បងគំរូគ្រប់គ្រងព្រៃឈើផ្សេងៗ | របាយការណ៍ត្រួតពិនិត្យ | | ● | ─ | ─▶ | FA |
| ១.៣ ការគ្រប់គ្រងព្រៃឈើ និងឧទ្យានជាតិ ត្រូវបានកែតំរូវនិងមានភាពប្រសើរឡើង ។ | ១.៣.១ អនុវត្តគំរូគ្រប់គ្រងឧទ្យានជាតិ និងរៀបចំផែនការសំរាប់ថែរក្សាតំបន់ការពារ ។ | ផែនការគ្រប់គ្រង ផែនទី គំរោងថវិកា សំរាប់សាធារណៈជន | | ● | ─ | ─▶ | DNCP |
| | ១.៣.២ ចាប់ផ្តើមធ្វើសនិទានកម្មព្រៃឈើ និង ចាត់ថ្នាក់ព្រៃឈើឡើងវិញ ។ | កំរងឯកសារនៃការសិក្សាអំពី ជីវវិទ្យា សង្គម និង សេដ្ឋកិច្ច ។ | | ● | ─ | ─● | FA/DNCP |
| | ១.៣.៣ គ្រប់គ្រងព្រៃឈើដោយផ្អែកតាមកម្មវិធីព្រៃឈើជាតិ ផែនការរយៈពេលមធ្យម-វែង និង ផែនការគ្រប់គ្រងព្រៃឈើរបស់រដ្ឋបាលព្រៃឈើ ។ | ផែនការគ្រប់គ្រងព្រៃឈើ ផែនទី និងគំរោងថវិកា ។ | | ● | ─ | ─▶ | FA |
| ១.៤ ការគ្រប់គ្រងព្រៃឈើបានប្រសើរឡើង តាមរយៈពង្រឹងការអនុវត្តន៍ច្បាប់ និងតុលាការដែលផ្តល់ចំណាប់អារម្មណ៍និងការលើកទឹកចិត្តដល់សហគមន៍មូលដ្ឋានចូលរួមក្នុងការគ្រប់គ្រងធនធានធម្មជាតិ ។ | ១.៤.១ បន្តតាមដាននិងរាយការណ៍ពីឧក្រិដ្ឋកម្មព្រៃឈើ និងដីធ្លី ។ | ទិន្នន័យរបស់ FCRM | ● | ─ | ─▶ | | FA/DNCP/ Juridical |
| | ១.៤.២ កែលំអប្រព័ន្ធតុលាការក្នុងការដោះស្រាយបទ ឧក្រិដ្ឋព្រៃឈើ (កំពុងរង់ចាំការគាំទ្រ) ។ | សាលក្រមរបស់តុលាការ | ● | ─ | ─▶ | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១.៥ អភិបាលកិច្ចព្រៃឈើមានភាពប្រសើរឡើង។ | ១.៥.១ ជំរុញអភិបាលកិច្ចល្អលើព្រៃឈើតាមរយៈភាពជាដៃគូក្នុងចំណោមអ្នកពាក់ពន្ធ័។ | កំណើនធនធានដែលផ្តល់ជូនអ្នកពាក់ពន្ធ័។ | ● | ─ | ─ | → | FA/DNCP |
| | ១.៥.២ បង្កើនតម្លាភាព ដោយបើកចំហពត៌មាន តាមរយៈគេហទំព័ររបស់ក្រុមការងារ: www.twgfe.org. | ចំនួនព័ត៌មានដែលទទួលបានពីបណ្តាអ្នកពាក់ពន្ធ័ផ្សេងៗ។ | ● | ─ | ─ | → | FA/DNCP |
| | ១.៥.៣ បន្តគាំទ្រតួនាទីលេខាធិការដ្ឋានក្រុមការងារ TWG-F&E និងជាចំណុចកណ្តាលសំរាប់សំរបសំរួលជំនួយ និងការរៀបចំផែនការ | របាយការណ៍វឌ្ឍនភាព និងកំណើនមូលនិធិផ្តល់តាមរយៈលេខាធិការដ្ឋាន TWG។ | ● | ─ | ─ | ─→ | TWG F&E |
| **គោលចំណងទី ២** | **ការអភិរក្ស និងការគ្រប់គ្រងប្រកបដោយនិរន្តរភាពនូវ ធនធានព្រៃឈើជាតិ និង ការដាំឈើដើម្បីជំនួសតំរូវការប្រើប្រាស់ឈើចេញពីព្រៃធម្មជាតិ** | | | | | | |
| **សមាសធាតុអភិវឌ្ឍន៍សំខាន់ៗ** | **ជំរុញការចូលរួមវិភាគទានរបស់ព្រៃឈើ និងការដាំឈើ ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច និង សង្គម។**<br>ពាក្យគន្លឹះ : **ការអភិរក្ស និង ការដាំព្រៃឈើឡើងវិញ** | | | | | | |
| ២.១ ការគ្រប់គ្រងតំបន់ការពារដោយមានការចូលរួម ដើម្បីផ្តល់ការងារដល់ប្រជាជននៅជនបទ។ | ២.១.១ បង្កើននិរន្តរភាពបរិស្ថាន ដោយជំរុញសកម្មភាពណាដែលមានផលប៉ះពាល់តិចៈ ធ្វើការវាយតំលៃផលប៉ះពាល់សង្គមនិងបរិស្ថាន សាកល្បងប្រពន្ធ័គ្រប់គ្រងក្នុងព្រៃឈើការពារ និងតំបន់ការពារ។ | ចំនួនព្រៃការពារ និងតំបន់ការពារស្ថិតនៅក្រោមការគ្រប់គ្រង | | ● | ─ | → | FA/DNCP |
| ២.២ ធនធានហ្សែនព្រៃឈើត្រូវបានអភិរក្ស សំរាប់ផ្តល់ពូជដល់កម្មវិធីដាំឈើ និងស្តារព្រៃធម្មជាតិឡើងវិញ។ | ២.២.១ រៀបចំនិងអភិរក្សធនធានហ្សែនព្រៃឈើគ្រប់តំបន់អេកូឡូស៊ី។ | គោលដៅក្នុងកម្មវិធី តូចៗ | ● | ─ | ● | | FA/DNCP |
| ២.៣ ការបង្កើតចំការឈើសំរាប់គោលដៅសេដ្ឋកិច្ចសង្គម។ | ២.៣.១ ដល់ឆ្នាំ២០១០ ដាំឈើឱ្យបាន៤០.០០០ ha សំរាប់ការប្រើប្រាស់ជាប្រយោជន៍សេដ្ឋកិច្ចសង្គម។ | ដាំឈើ ១០.០០០ ហិកតា ក្នុងមួយឆ្នាំ | ● | ─ | ─ | → | FA/ ឯកជន |
| | ២.៣.២ ណែនាំអំពីគោលការណ៍ និងដាំឈើរបស់ CDM | ចំនួនចំការឈើរបស់ CDM គិតជាហិកតា | ● | ● | | | FA/ឯកជន |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២.៤ គំរូគ្រប់គ្រងព្រៃក្រោយសម្បទានត្រូវបានសាកល្បង ។ | ២.៤.១ សាកល្បងគំរូគ្រប់គ្រងព្រៃឈើក្រោយព្រៃសម្បទាន ។ | ការសាកល្បងថ្មីមួយក្នុងមួយឆ្នាំ | | | | | FA |
| **គោលចំណងទី ៣** | **ជីវភាពនៅតំបន់ជនបទ ទទួលបានការគាំទ្រ តាមរយៈការចូលរួមជាអតិបរមាពីសំណាក់ ប្រជាជនមូលដ្ឋាននិងវិស័យឯកជន ក្នុងការគ្រប់គ្រងធនធានធម្មជាតិ ។** | | | | | | |
| **សមាសធាតុអភិវឌ្ឍន៍សំខាន់១** | **ជំរុញការគ្រប់គ្រងព្រៃឈើឱ្យចូលរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ ។**<br>ពាក្យគន្លឹះ : ***ការចូលរួមរបស់សហគមន៍ និង សហគ្រាសព្រៃឈើខ្នាតតូច-មធ្យម*** | | | | | | |
| ៣.១ ចំណេះដឹងអំពីជម្រើសគ្រប់គ្រងព្រៃឈើនិងសិទ្ធិប្រើប្រាស់ផលិតផលព្រៃឈើ មានភាពប្រសើរឡើង ។ | ៣.១.១ ពង្រីកកម្មវិធីសហគមន៍ព្រៃឈើឱ្យច្រើនបន្ថែមទៀត ។ | គោលដៅពង្រីកសហគមន៍ព្រៃឈើមានក្នុងកម្មវិធីសហគមន៍ព្រៃ ឈើ ។ | | | | | FA |
| | ៣.១.២ រៀបចំ និងអនុវត្តកម្មវិធីគ្រប់គ្រងតំបន់ការពារដោយមានការចូលរួមរបស់សហគមន៍ ។ | គោលដៅអនុវត្តកម្មវិធីមានក្នុងផែនការតំបន់ការពារ ។ | | | | | DNCP |
| | ៣.១.៣ សាកល្បងភាពជាដៃគូ និង គំរូគ្រប់គ្រងព្រៃឈើមានការចូលរួមឱ្យបាន១០កន្លែងមានទំហំ ១០.០០០ ហិកតា | គំរូថ្មីត្រូវបានអនុវត្ត | | | | | FA |
| | ៣.១.៤ ទទួលស្គាល់សិទ្ធិនិងការពារស្របច្បាប់ និង សិទ្ធិប្រពៃណី របស់ប្រជាជនមូលដ្ឋាន ក្នុងការប្រើប្រាស់ធនធានធម្មជាតិ ដើម្បីសន្តិសុខស្បៀង និងកាត់បន្ថយភាពក្រីក្រ ។ | ចំនួនករណីរំលោភបំពានផ្សព្វផ្សាយតាមប្រពន្ធ័ឃោសនា ត្រូវបានស៊ើបអង្កេត ។ | | | | | FA/DNCP |
| | ៣.១.៥ សិក្សាអំពីតំរូវការឈើនិងប្រភេទឈើ | តួរលេខតំរូវការឈើទូទាំងប្រទេស | | | | | FA/DNCP |
| | ៣.១.៦ ជំរុញសេវាកម្មបរិស្ថានតាមតំបន់សមស្រប ។ | ចំនួនទីតាំងថ្មីនៃតំបន់ទេសចរណ៍ធម្មជាតិស្ថិតក្រោមកិច្ចការពារពិសេស ។ | | | | | FA/DNCP |

| គោលចំណងទី៤ | ការចូលរួមរបស់បណ្តាអ្នកពាក់ព័ន្ធផ្សេងៗ ដើម្បីសុខដុមនីយកម្ម ទស្សនៈ ចំណាប់អារម្មណ៍ និង សមត្ថភាព របស់អ្នកពាក់ពន្ធ័ក្នុងវិស័យព្រៃឈើ ។ | | | | | | |
|---|---|---|---|---|---|---|---|
| **សមាសធាតុអភិវឌ្ឍន៍សំខាន់ៗ** | **ពង្រីកការយល់ដឹងជាសាធារណៈ និងពង្រឹងសមត្ថភាព ក្នុងការប្រើប្រាស់ធនធានធម្មជាតិ ។**<br>ពាក្យគន្លឹះ : **ការអភិវឌ្ឍន៍សមត្ថភាព** | | | | | | |
| ៤.១ សមត្ថភាពស្ថាប័នត្រូវបាន បង្កើន និងមានលទ្ធភាពផ្តល់ សេវាបច្ចេកទេស តាមតំរូវការ ។ | ៤.១.១ បន្តអនុវត្តកម្មវិធីពង្រឹងសមត្ថភាពទូទៅ ដោយផ្តោតលើការតាមដានលទ្ធផល ។ | លទ្ធផលយោងតាមផែនការ | ●——— | ——— | ——— | ——▶ | FA |
| | ៤.១.២ អភិវឌ្ឍន៍សមត្ថភាពក្នុងការដោះស្រាយបញ្ហាចំរុះនៅក្នុងការគ្រប់គ្រងធនធានធម្មជាតិ ។ | ចំនួនគំរោងសហប្រតិបត្តិការចំរុះ | | ●——● | | | FA/DNCP |
| | ៤.១.៣ រៀបចំ និងអនុវត្តកម្មវិធីស្រាវជ្រាវព្រៃឈើ និងសត្វព្រៃ ។ | ការរៀបចំកម្មវិធីចប់នៅចុងឆ្នាំ ២០០៧ និងចាប់ផ្តើមអនុវត្តនៅដើមឆ្នាំ ២០០៨ ។ | ●——● | ●—— | ▶ | | FA |
| | ៤.១.៤ រៀបចំសិក្ខាសាលាប្រចាំឆ្នាំដើម្បីពិភាក្សាអំពី បច្ចេកទេស ឬប្រធានបទណាមួយ ក្នុងក្រុមការងារបច្ចេកទេស ។ | របាយការណ៍សិក្ខាសាលា | ● | ——— | ——— | ——● | TWG Sec. |
| ៤.២ សមត្ថភាពចូលរួមរបស់ប្រជាជនក្នុងការគ្រប់គ្រងព្រៃឈើ និងឧទ្យានជាតិត្រូវបានបង្កើន ។ | ៤.២.១ ផ្សព្វផ្សាយចំណេះដឹងស្តីពីសិទ្ធិស្របច្បាប់ក្នុងការប្រើប្រាស់ ផលិតផលព្រៃឈើ ក្នុងតំបន់ព្រៃនិងតំបន់ការពារ និងរៀបចំជំរើសគ្រប់គ្រងព្រៃឈើរួមគ្នា ។ | ចំនួននិងប្រភេទនៃយុទ្ធនាការផ្សព្វផ្សាយការយល់ដឹង ។ | ● | ——● | | | FA/DNCP |
| | ៤.២.២ ពង្រឹងសមត្ថភាពសហគមន៍ក្នុងការចូលរួមគ្រប់គ្រងធនធានធម្មជាតិ ។ | កំណើននៃប្រព័ន្ធគ្រប់គ្រងដែលមានការចូលរួមត្រូវបានអនុវត្ត ។ | ●—— | ——— | ——— | ——▶ | FA/DNCP |

**សំគាល់ :** **កំពុងបន្ត :** ●——▶ **ចាប់ផ្តើម ហើយ បញ្ចប់ :** ●——●

## **ក្រុមការងារបច្ចេកទេសព្រៃឈើនិងបរិស្ថាន**
## **ផែនការ និង គំរោងថវិកា ឆ្នាំ២០០៧**

| សេចក្តីថ្លែងការណ៍គោលនយោបាយរួម: រាជរដ្ឋាភិបាលកម្ពុជា កំពុងជំរុញការគ្រប់គ្រងនិងអភិរក្សព្រៃឈើប្រកបដោយនិរន្តរភាពដើម្បីជាប្រយោជន៍សេដ្ឋកិច្ចសង្គមដល់ប្រជាជនកម្ពុជា ។ | | | | | |
|---|---|---|---|---|---|
| **គោលបំណងទី១** | ធនធានព្រៃឈើរបស់ប្រទេសត្រូវបានចាត់ទុកជាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ និង ការគ្រប់គ្រងធនធានធម្មជាតិមាននិរន្តរភាពចិរភាព ។ | | | | |
| សមាសធាតុអភិវឌ្ឍន៍សំខាន់ៗ | ពង្រឹងការគ្រប់គ្រង និងការអភិរក្ស ព្រៃឈើ<br>ពាក្យគន្លឹះ : **អភិបាលកិច្ចព្រៃឈើ** | | | | |
| លទ្ធផលរំពឹងទុក | សកម្មភាព | សូចនាករ | ស្ថាប័ន | ថវិកា | |
| | | | | តំរូវការ | បានសន្យា |
| ក្របខ័ណ្ឌយុទ្ធសាស្រ្តរួមមួយ សំរាប់វិស័យព្រៃឈើ: កម្មវិធីព្រៃ ឈើជាតិ ដើម្បីបង្កើនតម្លាភាព ការបញ្ជាក់ និងបង្ហាញច្បាស់អំពី ទិសដៅ និងសហប្រតិបត្តិការរវាងអ្នកពាក់ពន្ធ័ ហើយអនុលោមតាម យុទ្ធសាស្រ្តជាតិសំរាប់ការអភិវឌ្ឍន៍ ។ | ១. សំរបសំរួលក្របខណ្ឌ័ផែនការរួមគ្នា ក្នុងការរៀបចំផែនការ ថ្នាក់ជាតិ និងកម្មវិធីព្រៃឈើជាតិ ។ | បង្កើតក្រុម Task Force និងការជួល National Coordinator ។ របាយការណ៍ សេចក្តីថ្លែងការណ៍បេសកកម្ម និងផែនការ ។ | FA/Danida-Dfid | 100,000 | 30,000 |
| | ២. រៀបចំ និងកំណត់ព្រំដែនព្រៃឈើជាតិដើម្បីរក្សាគំរបព្រៃ ៦០% ។ | ផែនការ | FA/Danida-Dfid | 1,000,000 | 115,000 |
| | ៣. រៀបចំនិងអនុវត្តកម្មវិធីតូចៗសំរាប់វិស័យព្រៃឈើ ដែលជា សមាសធាតុក្នុងកម្មវិធីព្រៃឈើជាតិ ។ | កម្មវិធីតូចៗ | FA/Danida-Dfid | 1,000,000 | 50,000 |
| | ៤. រៀបចំ និងអនុវត្តផែនការគ្រប់គ្រងព្រៃឈើជាតិ ។ | ផែនការធំនិងតូចៗ | FA | 300,000 | |
| | ៥. វិភាគប្រសិទ្ធភាពរបបគ្រប់គ្រងព្រៃឈើផ្សេងៗដែលមាន សក្តានុពល ។ | របាយការណ៍វិភាគ | FA | 100,000 | |
| ការគ្រប់គ្រងទិន្នន័យ និង ពត៌មាន ដែលអាច ប្រើប្រាស់ សំរាប់ ការគ្រប់គ្រងព្រៃឈើ និង ការត្រួត ពិនិត្យ ។ | ៦. វាយតំលៃការប្រែប្រួលគំរបព្រៃឈើក្នុងតំបន់ដីសម្បទានសេដ្ឋកិច្ចមួយចំនួន ។ | ផែនទី និងទិន្នន័យ ឌីជីថល | FA/Danida-Dfid | 150,000 | 150,000 |
| | ៧. តាមដាន វាយតំលៃ និងរាយការណ៍អំពីការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព នៅអាស៊ី (GCP/Int./988/jpn). | បង្កើតគណៈកម្មាធិការដឹកនាំ បណ្តាញថ្នាក់ជាតិ ដើម្បីសុខដុមនីយ័កម្ម MAR/SFM | FA/FAO | 11,000 | 11,000 |
| ការគ្រប់គ្រងព្រៃឈើបានប្រសើរឡើង តាមរយៈពង្រឹងការអនុវត្តន៏ច្បាប់ និងតុលាការដែលផ្តល់ ចំណាប់អារម្មណ៏និងការលើកទឹកចិត្តដល់សហគមន៏មូលដ្ឋានចូលរួមក្នុងការគ្រប់គ្រងធនធានធម្មជាតិ ។ | ៨. បន្តតាមដាននិងរាយការណ៍ពីឧក្រិដ្ឋកម្មព្រៃឈើ និងដីធ្លី ។ | ទិន្នន័យ FCMR, សាលក្រមតុលាការ | FA | 50,000 | |
| | ៩. ពង្រឹងសមត្ថភាពអនុវត្តច្បាប់ព្រៃឈើ និងអភិបាលកិច្ចនៅកម្ពុជា ។ | រៀបចំសំណើគំរោង | FA/ITTO | 76,000 | 76,000 |
| អភិបាលកិច្ចព្រៃឈើមានភាព ប្រសើរឡើង ។ | ១០. បង្កើនតំលាភាព ដោយបើកចំហព័ត៌មានតាមរយៈគេហទំព័ររបស់ក្រុមការងារ www.twgfe.org. និងការបោះពុម្ពផ្សាយ ។ | ចំនួនព័ត៌មានដែលទទួលបានពីបណ្តាអ្នកពាក់ព័ន្ធផ្សេងៗ ។ | FA/Danida-Dfid | 12,600 | 12,600 |

| | | | | | |
|---|---|---|---|---|---|
| | ១១. បន្តគាំទ្រតួនាទីលេខាធិការដ្ឋាន TWG-F&E ដើម្បីក្លាយជាចំណុចកណ្ដាលសំរាប់ការសំរបសំរួល និងការរៀបចំផែនការ ។ | របាយការណ៏វឌ្ឍនភាព និងកំណើនមូលនិធិផ្ដល់តាមរយៈលេខាធិការដ្ឋាន TWG. | FA/Danida-Dfid | 100,000 | 64,400 |
| **គោលបំណងទី២** | **ការអភិរក្ស និងការគ្រប់គ្រងប្រកបដោយនិរន្តរភាពនូវធនធានព្រៃឈើជាតិ និងការដាំឈើដើម្បីជំនួសតំរូវការប្រើប្រាស់ឈើ ចេញពីព្រៃធម្មជាតិ** | | | | |
| សមាសធាតុអភិវឌ្ឍន៏សំខាន់ៗ | **ជំរុញការចូលរួមវិភាគទានរបស់ព្រៃឈើ និងការដាំឈើ ក្នុងការអភិវឌ្ឍន៏សេដ្ឋកិច្ច និង សង្គម ។**<br>ពាក្យគន្លឹះ : **ការអភិរក្ស និង ការដាំព្រៃឈើឡើងវិញ** | | | | |
| ធនធានហ្សែនព្រៃឈើត្រូវបាន អភិរក្ស សំរាប់ផ្ដល់ពូជដល់កម្មវិធីដាំ ឈើ និងស្ដារព្រៃធម្មជាតិឡើងវិញ ។ | ១២. រៀបចំនិងអភិរក្សធនធានហ្សែនព្រៃឈើគ្រប់តំបន់អេកូឡូស៊ី ។ | គោលដៅស្របទៅតាមគោលដៅនៅក្នុងកម្មវិធីតូចៗ ។ | FA/Danida-Dfid | 64,100 | 64,100 |
| ការបង្កើតចំការឈើសំរាប់ គោលដៅសេដ្ឋកិច្ចសង្គម ។ | ១៣. ដាំឈើឱ្យបាន១០.000 ហិកតា សំរាប់ការប្រើប្រាស់ជាប្រយោជន៏សេដ្ឋកិច្ចសង្គម ។ | ដាំឈើឱ្យបាន១០.000ហិកតាក្នុងឆ្នាំ២00៧ | FA/Private | 5,000,000 | |
| | ១៤. ណែនាំអំពីគោលការណ៏ និងដាំឈើរបស់ CDM ។ | ធ្វើឱ្យប្រសើរឡើងនូវចំណេះដឹងអំពី CDM | FA/AFD | 150,000 | |
| គំរូគ្រប់គ្រងព្រៃក្រោយសម្ប ទានត្រូវបានសាកល្បង ។ | ១៥. សាកល្បងគំរូគ្រប់គ្រងព្រៃឈើក្រោយព្រៃសម្បទាន ។ | ពិសោធន៏១កន្លែងសំរាប់១ឆ្នាំ ។ | FA/Danida-Dfid | 120,000 | 120,000 |
| | ១៦. អនុវត្តកម្មវិធីអភិរក្សព្រៃការពារនៅតំបន់ជួរភ្នំក្រវាញកណ្ដាល ។ | បានបញ្ជាក់ក្នុងអនុសារណៈរវាងក្រសួងកសិកម្ម និងអង្គការ CI ។ | FA/CI-AFD | 780,000 | 780,000 |
| **គោលបំណងទី៣** | **ជីវភាពនៅតំបន់ជនបទ ទទួលបានការគាំទ្រ តាមរយៈការចូលរួមជាអតិបរមាពីសំណាក់ ប្រជាជនមូលដ្ឋាននិងវិស័យឯកជន ក្នុងការគ្រប់គ្រងធនធានធម្មជាតិ ។** | | | | |
| សមាសធាតុអភិវឌ្ឍន៏សំខាន់ៗ | **ជំរុញការគ្រប់គ្រងព្រៃឈើឱ្យចូលរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ ។**<br>ពាក្យគន្លឹះ : **ការចូលរួមរបស់សហគមន៍ និង សហគ្រាសព្រៃឈើធុនតូច_មធ្យម** | | | | |
| ចំណេះដឹងអំពីជំរើសគ្រប់គ្រងព្រៃឈើនិងសិទ្ធិប្រើប្រាស់ផលិតផលព្រៃឈើ មានភាពប្រសើរឡើង ។ | ១៧. ពង្រីកកម្មវិធីសហគមន៏ព្រៃឈើឱ្យច្រើនបន្ថែមទៀត ។ (FAO: Community forestry development in North-Western Cambodia 2006-08: $350,000) | គោលដៅពង្រីកសហគមន៏ព្រៃឈើមានក្នុងកម្មវិធីសហគមន៏ព្រៃឈើ ។ | FA/Danida-Dfid/FAO | 490,000 | 490,000 |
| | ១៨. រៀបចំ និងអនុវត្តកម្មវិធីគ្រប់គ្រងតំបន់ការពារដោយមានការចូលរួមរបស់សហ គមន៏ ។ | គោលដៅអនុវត្តកម្មវិធីមានក្នុងផែនការតំបន់ការពារ ។ | DNCP | 100,000 | |
| | ១៩. សិក្សាអំពីតំរូវការផលិតផលឈើ និង biomass ក្នុងស្រុកនិងអន្តរជាតិ ។ | របាយការណ៏ | FA/Danida-Dfid | 100,000 | 100,000 |

| | | | | | |
|---|---|---|---|---|---|
| | ២០. ធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងនិងប្រើប្រាស់អនុផលព្រៃឈើនៅកម្ពុជាឱ្យមាននិរន្តរភាព។ | សមាគម/ក្រុមប្រមូលផលមានភាពប្រសើរ ដោយសហការជាមួយរដ្ឋព្រៃឈើ។ ផែនការគ្រប់គ្រងរបស់សហគមន៍ស្របតាមប្រព័ន្ធកម្មសិទ្ធិដីធ្លី។ | FA/ITTO | 60,800 | 60,800 |
| **គោលបំណងទី៤** | **ការចូលរួមរបស់បណ្តាអ្នកពាក់ព័ន្ធផ្សេងៗ ដើម្បីសុខដុមនីយកម្ម ទស្សនៈ ចំណាប់អារម្មណ៍ និង សមត្ថភាព របស់អ្នកពាក់ពន្ធ័ក្នុងវិស័យព្រៃឈើ។** | | | | |
| សមាសធាតុអភិវឌ្ឍន៏សំខាន់៧ | **ពង្រីកការយល់ដឹងជាសាធារណៈ និងពង្រឹងសមត្ថភាព ក្នុងការប្រើប្រាស់ធនធានធម្មជាតិ។**<br>ពាក្យគន្លឹះ : **ការអភិវឌ្ឍន៍សមត្ថភាព** | | | | |
| សមត្ថភាពស្ថាប័នត្រូវបានបង្កើន និងមានលទ្ធភាពផ្តល់សេវា បច្ចេកទេស តាមតំរូវការ។ | ២០. បន្តអនុវត្តកម្មវិធីពង្រឹងសមត្ថភាពទូទៅ ដោយផ្តោតលើការ តាមដានលទ្ធផល។ | លទ្ធផលយោងតាមផែនការ | FA/JICA | 800,000 | 800,000 |
| | ២២. រៀបចំ និងអនុវត្តកម្មវិធីស្រាវជ្រាវព្រៃឈើ និងសត្វព្រៃ។ | ការរៀបចំកម្មវិធីចប់នៅចុងឆ្នាំ ២០០៧ និងចាប់ផ្តើមអនុវត្តនៅដើមឆ្នាំ ២០០៨។ | FA | 200,000 | |
| | ២៣. រៀបចំសិក្ខាសាលាប្រចាំឆ្នាំដើម្បីពិភាក្សាអំពី បច្ចេកទេស ឬ ប្រធានបទណាមួយក្នុងក្រុមការងារបច្ចេកទេស។ | របាយការណ៍សិក្ខាសាលា | TWG /Danida-Dfid | 2,000 | 2,000 |
| | ២៤. គាំទ្រមន្ត្រីរដ្ឋបាលព្រៃឈើម្នាក់ទៅសិក្សាថ្នាក់អនុបណ្ឌិតផ្នែក GIS ។នៅសាកលវិទ្យាល័យ AIT (2007-08) | មន្ត្រីរដ្ឋបាលព្រៃឈើ១រូបបានបញ្ចប់ការសិក្សាជាស្ថាពរ។ | TWG /Danida-Dfid | 15,000 | 15,000 |
| | ២៥. ផ្សព្វផ្សាយចំណេះដឹងស្តីពីសិទ្ធិស្របច្បាប់ក្នុងការប្រើប្រាស់ផលិតផលព្រៃឈើ ក្នុងតំបន់ព្រៃនិងតំបន់ការពារ និងរៀបចំជំរើសគ្រប់គ្រងព្រៃឈើរួមគ្នា។ | ចំនួននិងប្រភេទនៃយុទ្ធនាការផ្សព្វផ្សាយការយល់ដឹង។ | FA | 50,000 | 50,000 |
| | ២៦. គាំទ្រដល់ ការពិភាក្សាស្តីពីវិស័យព្រៃឈើនៅក្នុងស្រុក និងអន្តរជាតិ។ | ចំនួននៃមន្ត្រីរដ្ឋបាលព្រៃឈើចូលរួម UNFF, COFO និងសិក្ខាសាលាជាតិ។ | FA/Danida-Dfid | 36,000 | 36,000 |
| សមត្ថភាពចូលរួមរបស់ប្រជាជនក្នុងការគ្រប់គ្រង ព្រៃឈើ និង ឧទ្យានជាតិត្រូវបានបង្កើន។ | ២៧. ពង្រឹងសមត្ថភាពសហគមន៍ក្នុងការចូលរួមគ្រប់គ្រងធនធានធម្មជាតិ។ | កំណើននៃប្រព័ន្ធគ្រប់គ្រងដែលមានការចូលរួមត្រូវបានអនុវត្ត។ | FA | 100,000 | |
| **ថវិកាសរុប** | | | | **10,967,500** | **3,026,900** |

***សំគាល់***

FA = រដ្ឋបាលព្រៃឈើ

TWG = ក្រុមការងារបច្ចេកទេស